# ការទទួលខុសត្រូវសង្គម ៖
# ការចាប់ផ្តើមស្គាល់ពី ទស្សនាទាន និង ការអនុវត្តជាក់ស្តែង

## ក. ការចាប់ផ្តើមស្គាល់ដោយវែកញែកពីការទទួលខុសត្រូវសង្គម

សារសំខាន់របស់រដ្ឋាភិបាលចាំបាច់មានការទទួលខុសត្រូវ ចំពោះប្រជាពលរដ្ឋ ដែលបានដាក់ជាគោលការណ៍នៅក្នុងសេចក្តីថ្លែងការគោលនយោបាយរបស់ធនាគារពិភពលោកនាពេលបច្ចុប្បន្ននេះ។ របាយការណ៍ស្តីពីការអភិវឌ្ឍពិភពលោកនៅឆ្នាំ ២០០១ និងក្របខ័ណ្ឌផ្តល់អំណាចដល់ប្រជាពលរដ្ឋរបស់ធនាគារពិភពលោកបានទទួលស្គាល់ការទទួលខុសត្រូវថាជាសមាសភាពចម្បងនៃ "ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ" និងនាំដល់ការកាត់បន្ថយភាពក្រីក្រ។ តម្រូវការសំរាប់ពង្រឹងទំនាក់ទំនងនៃការទទួលខុសត្រូវជាមួយ អ្នកធ្វើគោលនយោបាយ អ្នកផ្តល់សេវា និងអ្នកប្រើប្រាស់សេវា មានចែងច្បាស់ជាសេចក្តីសំអាងស្នូលនៅក្នុងរបាយការណ៍ពីការអភិវឌ្ឍពិភពលោកឆ្នាំ ២០០៤ ដើម្បី "ធ្វើឱ្យសេវាទាំងឡាយបម្រើអ្នកក្រីក្រ" ។ លើសពីនេះ ការទទួលខុសត្រូវរបស់ស្ថាប័នទាំងឡាយ គឺជាសសរទ្រូងមួយក្នុងចំណោមសសរទ្រូងបី ដែលជាយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមផុសឡើងដោយធនាគារពិភពលោក ។

តាំងពីយូរមក កិច្ចខិតខំប្រឹងប្រែងក្នុងការដោះស្រាយការប្រឈមប្រជែងនៃការទទួលខុសត្រូវមានទំនោរផ្តោតតែទៅលើការពង្រីក "**ភាគីផ្នែកផ្តល់**" សេវាអភិបាលកិច្ច តាមមធ្យោបាយដូចជា ៖ ការថ្លឹងថ្លែង និងការត្រួតពិនិត្យនយោបាយ បែបបទនិងបទបញ្ជាផ្នែករដ្ឋបាល សវនកម្ម និង ត្រូវមានភ្នាក់ងាររដ្ឋជំរុញការអនុវត្តច្បាប់ ដូចជាតុលាការ និង នគរបាលជាដើម ។ នៅប្រទេសជាច្រើន យន្តការលើកកម្ពស់ការទទួលខុសត្រូវ "**ពីលើមកក្រោម**" ទាំងនេះមិនបានទទួលជោគជ័យទាំងស្រុងឡើយ ទោះបីជាប្រទេសដែលរីកចម្រើន ឬ កំពុងអភិវឌ្ឍក៏ដោយ។ បន្តមក វិធានការណ៍ថ្មីៗ ដូចជា ការបង្កើតភ្នាក់ងារគាំទ្រការទទួលខុសត្រូវឯករាជ្យ ដែលមានគណៈកម្មការឃ្លាំមើល និង អ្នកសង្កេតការណ៍សាធារណៈជាដើម ត្រូវបានសាកល្បង ហើយវិធានខ្លះទៀតមានការប្រែស្ថាប័នរដ្ឋទៅជាឯកជន ឬការធ្វើកិច្ចសន្យាជាមួយផ្នែកឯកជនឱ្យផ្តល់សេវា ដើម្បីព្យាយាមឱ្យមានការទទួលខុសត្រូវតាមបែបទីផ្សារ នៅក្នុងសេវាកម្មរបស់ផ្នែករដ្ឋ ។

ថ្មីៗនេះ មានការយកចិត្តទុកដាក់កើនឡើងលើ "**ភាគីផ្នែកទទួល**" សេវាអភិបាលកិច្ច គឺពង្រឹងសំឡេង និងសមត្ថភាពរបស់ប្រជាពលរដ្ឋ (ជាពិសេសអ្នកក្រីក្រ) ដើម្បីបំផុសសេចក្តីចំពោះការទទួលខុសត្រូវ និងការឆ្លើយតបពីមន្ត្រី និង អ្នកផ្តល់សេវាសាធារណៈ ។ ការបង្កើនលទ្ធភាពដល់ប្រជាពលរដ្ឋឱ្យចូលរួមខ្វាប់ខ្ជួន ជាមួយមន្ត្រីរាជការ និង អ្នកនយោបាយ ដោយព័ត៌មានស្អិតរមួត ដោយផ្ទាល់ និង ដោយស្ថាបនា គឺជា ការអនុវត្តការ

ទទួលខុសត្រូវសង្គម ដែលរំលេចឡើងក្នុងឯកសារនេះ ។ ចំណាប់អារម្មណ៍ និងការគិតគូររបស់ធនាគារពិភពលោកក្នុងរឿង **"ការទទួលខុសត្រូវសង្គម"** កើតឡើងចេញពីគោលដៅស្នូលរបស់ធនាគារក្នុងការជំរុញការកាត់បន្ថយភាពក្រីក្រ រួមទាំងការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និង ចីរភាព។ ធនាគារបង្ហាញពីការកាន់តែយកចិត្តទុកដាក់ទៅលើបញ្ហាអភិបាលកិច្ច ការផ្តល់អំណាច និង វិធីសាស្ត្រអភិវឌ្ឍន៍ដោយផ្អែកលើសិទ្ធិ។

បំណងនៃឯកសារនេះ គឺដើម្បីបកស្រាយបញ្ជាក់ពីទស្សនាទាននៃការទទួលខុសត្រូវសង្គម និង ដើម្បីពន្យល់ដោយសង្ខេបពីសេចក្តីសំខាន់ ជា ធាតុគន្លឹះ និងការប្រតិបត្តិតាមមេរៀនជាបទពិសោធន៍ ដែលបានផ្តួចផ្តើមធ្វើរួចមកហើយក្នុងសកលលោក ។ ឯកសារនេះមិនអធិប្បាយលម្អិតពីឧបករណ៍ក្នុងការ ទទួលខុសត្រូវសង្គមនោះទេ ហើយក៏មិនផ្តល់ការវិភាគទស្សនាទានឱ្យបានល្អិតល្អន់ដែរ ។ ប៉ុន្តែគោលបំណង នៃឯកសារនេះ គឺដើម្បីបង្ហាញទិដ្ឋភាពទូទៅដែលខ្លី ចំៗពីសញ្ញាណនៃការទទួលខុសត្រូវសង្គម ពីសារៈសំខាន់ និង លក្ខណៈរបស់វា ។

ផ្នែកបន្ទាប់នៃឯកសារនេះនឹងបង្ហាញនិយមន័យ និង រំលេចឱ្យឃើញពីគ្រោងការណ៍ជាទស្សនាទាននៃការទទួលខុសត្រូវសង្គម ។ សារៈសំខាន់ និងការជាប់ទាក់ទងនៃទស្សនាទាននេះ ក៏ដូចជាការជាប់ពាក់ព័ន្ធរបស់វាជាមួយប្រធានបទក្នុងរឿងអភិវឌ្ឍន៍សំខាន់ៗ នឹងត្រូវបានពិភាក្សាផងដែរ ។ ផ្នែកទី ៣ នឹងបង្ហាញ ពីធាតុជាគន្លឹះ ឬ "សមាសភាពសំណង់" នៃគំនិតដើមរបស់ការទទួលខុសត្រូវសង្គម ។ ផ្នែកទី ៤ នឹងអធិប្បាយពីការប្រើប្រាស់ និង ឧបករណ៍នៃការទទួលខុសត្រូវសង្គម ហើយផ្នែកទី ៥ នឹងបន្តដោយរាយចេញនូវ កត្តាសំខាន់ៗដែលកំណត់ភាពជោគជ័យនៃគំនិតដើមរបស់ការទទួលខុសត្រូវសង្គម។ ជាបញ្ចប់ផ្នែកទី ៦ ផ្តល់នូវកំណត់សម្គាល់សរុបបញ្ចប់សេចក្តី ។

## ២. គ្រោងការណ៍ជាទស្សនាទាននៃការទទួលខុសត្រូវសង្គម

### តើអ្វីជាការទទួលខុសត្រូវ?

ដើម្បីពន្យល់ពីទស្សនាទាននៃការទទួលខុសត្រូវសង្គម ចាំបាច់ត្រូវយល់ច្បាស់ពីនិយមន័យនៃ (ពាក្យ) ការទទួលខុសត្រូវ ជាមុនសិន ។

**ការទទួលខុសត្រូវ** គឺជា កាតព្វកិច្ចនៃអ្នកកាន់អំណាចក្នុងការអធិប្បាយបង្ហាញ ឬ ក្នុងការទទួលរ៉ាប់រងលើរាល់ទង្វើរបស់ខ្លួន ។ "អ្នកកាន់អំណាច" សំដៅដល់អ្នកទាំងឡាយដែលមានឥទ្ធិពលផ្នែកនយោបាយ ហិរញ្ញវត្ថុ ឬអនុភាពផ្នែកផ្សេងៗ ហើយរួមបញ្ចូលទាំងមន្ត្រីរដ្ឋ ឬ រាជការ ផ្នែក ឬ ក្រុមហ៊ុនឯកជន ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និង អង្គការសង្គមស៊ីវិល ។

ឯកសារនេះផ្តោតជាពិសេសលើការទទួលខុសត្រូវរបស់មន្ត្រីរដ្ឋការ ឬ រាជការ ចំពោះប្រជាពលរដ្ឋ និងជាពិសេសទៀតដល់ជនក្រីក្រ ។ ការទទួលខុសត្រូវនេះ គឺជាកម្មវត្ថុសំខាន់នៃ "កិច្ចព្រមព្រៀងសង្គម" ដែលបង្កប់ ឬ (វាទរហិត) រវាងប្រជាពលរដ្ឋ និងតំណាង ក៏ដូចជាភ្នាក់ងារដែលទទួលប្រតិភូកម្មអំណាច តាមលក្ខណៈប្រជាធិបតេយ្យ ។ គោលការណ៏គ្រឹះនៃប្រជាធិបតេយ្យ គឺប្រជាពលរដ្ឋមានសិទ្ធិទាមទារការទទួលខុសត្រូវ និងទាមទារឱ្យអ្នកដើរតួសាធារណៈនានាបំពេញកាតព្វកិច្ចដើម្បីទទួលខុសត្រូវ ។ ដូចក្នុងគំនិតរបស់ **ម៉ាលកង់** បានបញ្ជាក់ថា : "អ្នកទាំងឡាយដែលអំពាវនាវរកការទទួលខុសត្រូវ នឹងត្រូវទាមទាររកសិទ្ធិ ដែលមានអំណាចធំជាង (ឆន្ទានុសិទ្ធិ)លើអ្នកទាំងឡាយដែលត្រូវទទួលខុសត្រូវ" ។ មន្ត្រី និង ការិយាល័យរដ្ឋាភិបាលទាំងឡាយត្រូវទទួលខុសត្រូវលើ (១)ការដឹកនាំ (២)សកម្មភាពការងាររបស់ខ្លួន ។ និយាយម្យ៉ាងទៀត គឺមន្ត្រី និងការិយាល័យរដ្ឋាភិបាលអាច និងគួរតែត្រូវបានដាក់កំហិតឱ្យ (១)គោរពច្បាប់ និងមិនរំលោភ អានុភាពនៃអំណាច និង (២)បម្រើប្រយោជន៍សាធារណៈ ប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និង យុត្តិធម៌។

រដ្ឋទាំងឡាយមានយន្តការផ្សេងៗគ្នា ក្នុងការលើកកម្ពស់ និង ធានាការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈ ។ ប្រព័ន្ធនៃការទទួលខុសត្រូវផ្ទៃក្នុងរបស់រដ្ឋ ហៅថាយន្តការបណ្តោយនៃការទទួលខុសត្រូវ ។ យន្តការទាំងនេះរួមបញ្ចូល (១)យន្តការនយោបាយ មានដូចជា : លក្ខខណ្ឌរដ្ឋធម្មនុញ្ញ ការបែងចែកអំណាចអង្គនីតិបញ្ញត្តិ និងគណៈកម្មការស៊ើបអង្កេតនៃអង្គនីតិបញ្ញត្តិ... (២)យន្តការហិរញ្ញវត្ថុ មានដូចជា : ប្រព័ន្ធសវនកម្ម និងគណនេយ្យហិរញ្ញវត្ថុផ្លូវការ... (៣)យន្តការរដ្ឋបាល មានដូចជា : ឋានានុក្រមក្នុងការរាយការណ៍ ទម្រង់ការណ៏នៃការងាររបស់ផ្នែកសាធារណៈ គោលការណ៏នៃសេវាសាធារណៈ បទបញ្ជា និងបែបបទចំពោះតម្លាភាព និងចំពោះមុខមាត់សាធារណៈ... និង (៤)យន្តការច្បាប់ មានដូចជា : ភ្នាក់ងារត្រួតពិនិត្យអំពើពុករលួយមន្ត្រីតាមដានមុខងារសាធារណៈ និង ប្រព័ន្ធតុលាការ ។

មានមតិយោបល់ខុសគ្នាគួរឱ្យកត់សម្គាល់ ក្នុងចំណោមអ្នកប្រាជ្ញខាងការទទួលខុសត្រូវ អំពីពីថាតើត្រូវឱ្យនិយមន័យលើទស្សនាទាននៃការទទួលខុសត្រូវ យ៉ាងណាឱ្យខ្លី ចំ ឬ ឱ្យគ្រប់ជ្រុងជ្រោយនោះឡើយ។ ដូចជា អ្នកខ្លះឱ្យនិយមន័យការទទួលខុសត្រូវថាជា **បាតុភូតមុន-ក្រោយ** ឯខ្លះទៀតយល់ថាជា គោលការណ៏នៃការទទួលខុសត្រូវគួរតែអនុវត្តនៅមុន ក្នុងអំឡុងពេល និង ក្រោយពីការប្រើអំណាចសាធារណៈជាការល្អ ។ ទាក់ទងទៅនឹងពេល **មុន/ក្រោយ**ការពិភាក្សាដែលមានក្នុងពេលមុន អ្នកអង្កេតខ្លះបែរជាអះអាង ដើម្បីញែករវាងការឆ្លើយតបរបស់រដ្ឋាភិបាល ជាមួយនឹងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដែលមួយសំដៅដល់របៀប ដែលរដ្ឋាភិបាលឆ្លើយតបទៅសេចក្តីត្រូវការដែលបង្ហាញដោយប្រជាពលរដ្ឋ និងមួយទៀតសំដៅដល់ការដែលប្រជាពលរដ្ឋអាចដាក់កំហិតឱ្យរដ្ឋាភិបាលគោរពការសន្យារបស់ខ្លួន ។ អ្នកប្រាជ្ញខ្លះទៀត បានយល់ស្របលើភាពខុសប្លែកគ្នានៃទស្សនាទានទាំងពីរ ហើយក៏យល់ថាទាំងពីរនេះជាដៃឆ្វេង និងដៃស្តាំ ហើយថែមទាំងយល់ថា

មិនចាំបាច់ញែកឱ្យដាច់ពីគ្នានោះទេ ។ ឯកសារនេះ ក្នុងមូលបទដើម្បីការយល់ដឹងពីទស្សនាទាន និង ការអនុវត្តជាក់ស្តែង ចាត់ទុកទស្សនាទានទាំងពីរថាមានទំនាក់ទំនងមិនអាចកាត់ផ្តាច់បាន ។ ហេតុដូចនេះ វាបង្ហាញពីយន្តការដែលលើកស្ទួយទាំងការឆ្លើយតប និង ការទទួលខុសត្រូវ នៅជំហាននានា ក្នុងការកសាងការអនុវត្តការតាមដាន និង វាយតម្លៃលើគោលនយោបាយ និង កម្មវិធីនានារបស់រដ្ឋាភិបាល ។

## តើអ្វីទៅជាការទទួលខុសត្រូវសង្គម?

ទទួលខុសត្រូវសង្គមអាចឱ្យនិយមន័យថាជា***វិធីសាស្ត្រមួយក្នុងការកសាងការទទួលខុសត្រូវដែលអាស្រ័យដោយការចូលរួមដ៏ខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋ មានដូចជាប្រជាពលរដ្ឋធម្មតា និង/ឬអង្គការសង្គមស៊ីវិលចូលរួមដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងការទទួលខុសត្រូវពិតប្រាកដ*** ។ យន្តការនៃការទទួលខុសត្រូវសង្គមអាចត្រូវបានផ្តួចផ្តើម និងគាំទ្រពីភាគីរដ្ឋ ភាគីប្រជាពលរដ្ឋ ឬ ទាំងពីរភាគី ប៉ុន្តែជាទូទៅគឺ ***ផុសចេញពីតម្រូវការ*** ហើយមានដំណើរការពីក្រោមឡើងទៅលើ ។

យន្តការនៃការទទួលខុសត្រូវសង្គម ជួនកាលហៅថាជាយន្តការនៃការទទួលខុសត្រូវ បែប "ខាងក្រៅ" ឬ "ខ្សែឈរ" (ផ្ទុយពីយន្តការនៃការទទួលខុសត្រូវតាមទម្លាប់បែប "ខាងក្នុង" ឬ "ខ្សែបណ្តោយ" ដែលបានពិភាក្សាពីខាងដើម) ។ យន្តការនៃការទទួលខុសត្រូវបែប "ខ្សែឈរ" មានចំណុចសំខាន់មួយ ក្នុងរដ្ឋប្រជាធិបតេយ្យនោះគឺការបោះឆ្នោត ។ ការបោះឆ្នោតតែមួយមុខ ទោះជាយ៉ាងណាវាជាឧបករណ៍ឬលមិនមានប្រសិទ្ធភាពសម្រាប់ចាប់ឱ្យរដ្ឋាភិបាលទទួលខុសត្រូវបានទេ ។ ទោះបីជាប្រជាពលរដ្ឋទទួលបានព័ត៌មានពេញលេញ និង ត្រឹមត្រូវ ពីអាកប្បកិរិយា និង សកម្មភាពរបស់បេក្ខជននយោបាយនីមួយៗ យ៉ាងណាក្តី (ព្រោះវាមិនជាប់ពាក់ព័ន្ធដោយផ្ទាល់) ក៏ការបោះឆ្នោតបានទុកលទ្ធភាពឱ្យគេនៅត្រឹមតែរើសក្នុងចំណោមបុគ្គល ឬ គណបក្សនយោបាយដែលមានចំនួនកំណត់តែប៉ុណ្ណោះ ។ គេមិនផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបង្ហាញការពេញចិត្តលើបញ្ហាណាមួយ ឬ ឱ្យចូលរួមក្នុងការសម្រេចចិត្តសាធារណៈដ៏មានអត្ថន័យ ហើយក៏មិនផ្តល់ឱកាសឱ្យទាមទាររកការទទួលខុសត្រូវពីអ្នកបំពេញការងារសាធារណៈ លើការសម្រេចចិត្ត និង ទង្វើណាមួយឡើយ ។

ហេតុនេះការទទួលខុសត្រូវសង្គម សំដៅដល់សកម្មភាព និងយន្តការជាច្រើនបែបយ៉ាង (លើសពីការបោះឆ្នោត) ដែលប្រជាពលរដ្ឋ សហគមន៍ អង្គការសង្គមស៊ីវិល និង ផ្នែកផ្សព្វផ្សាយឯករាជ្យនានា អាចប្រើដើម្បីទាមទារមន្ត្រី និង អ្នកផ្តល់សេវាសាធារណៈឱ្យមានការទទួលខុសត្រូវ ។ តាមទម្លាប់ អ្វីៗទាំងនេះ រួមបញ្ចូលទាំងប្រជាពលរដ្ឋគ្រប់លំដាប់ថ្នាក់ ឬ សកម្មភាពដែលដឹកនាំដោយសង្គមស៊ីវិល ដូចជាបាតុកម្មសាធារណៈ, ការតវ៉ាយុទ្ធនាការតស៊ូមតិ ការចុះការសែតពីលទ្ធផលស៊ើបអង្កេត និង បណ្តឹងផ្លូវច្បាប់ពីប្រយោជន៍សាធារណៈ ជាដើម ។

ប៉ុន្មានឆ្នាំចុងក្រោយនេះ អាស្រ័យមានការរីករាលដាលក្នុងការប្រើប្រាស់វិធីសាស្ត្រប្រមូលទិន្នន័យ ដោយមានការចូលរួម និង ឧបករណ៍វិភាគកាន់តែទូលំទូលាយ គួបផ្សំជាមួយ (ក្នុងបរិបទប្រទេសជាច្រើន) ការបើកចំហ និងទុកឱកាសរិតតែច្រើនឱ្យប្រជាពលរដ្ឋ ក៏ដូចជាការចូលរួមដ៏ខ្ជាប់ខ្ជួនរបស់សង្គមស៊ីវិល ជាមួយនឹងរដ្ឋ កត្តាទាំងអស់នេះ បាននាំឱ្យមានការអនុវត្តការទទួលខុសត្រូវសង្គមបែបជំនាន់ថ្មី ដែលសង្កត់ធ្ងន់លើមូលដ្ឋាន សភាពជាក់ស្តែងជាតឹកតាងយ៉ាងបួងមាំ និង លើអន្តរសកម្មភាព (សកម្មភាពទៅវិញទៅមក) ដោយផ្ទាល់ជាមួយផ្នែកដៃគូនានារបស់រដ្ឋាភិបាល ។ ទាំងនេះរួមមានដូចជា ការធ្វើបទបញ្ជាសាធារណៈដោយមានការចូលរួម ការធ្វើគម្រោងថវិកាដោយមានការចូលរួម កំណត់ត្រាចំណាយសាធារណៈ ការតាមដាន និង វាយតម្លៃលើការផ្តល់សេវាសាធារណៈរបស់ប្រជាពលរដ្ឋ ជាដើម ហើយក៏មានរួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែង ក្នុងការបង្កើនចំណេះដឹងរបស់ប្រជាពលរដ្ឋ និង បង្កើនការប្រើប្រាស់យន្តការនៃការទទួលខុសត្រូវតាមទម្លាប់ (ដូចមានតាមរយៈការអប់រំសាធារណៈអំពីសិទ្ធិតាមច្បាប់ និងសេវានានាដែលអាចរកបាន) និង/ឬកិច្ចខិតប្រឹងប្រែងក្នុងការបង្កើនប្រសិទ្ធភាពនៃយន្តការទទួលខុសត្រូវ "ផ្ទៃក្នុង" (ដូចមានតាមរយៈការដឹងឮ និងការចូលរួមពាក់ព័ន្ធរបស់ប្រជាពលរដ្ឋនៅក្នុងគណៈកម្មការសាធារណៈ ក្រុមប្រជាពលរដ្ឋផ្តល់ប្រឹក្សាយោបល់ និងគណៈកម្មាធិការមើលការខុសត្រូវ ។

ហេតុនេះ យន្តការទទួលខុសត្រូវសង្គម គឺដើម្បីបំពេញបង្គ្រប់ និងលើកស្ទួយយន្តការនៃ ការទទួលខុសត្រូវតាមទម្លាប់ផង ។ "ផ្នែកខាងក្នុង" គឺរដ្ឋ "ផ្នែកខាងក្រៅ" គឺសង្គម ដែលជាផ្នែកនៃយន្តការទទួលខុសត្រូវ អាចនិងគួរតែជំរុញឱ្យមានដំណើរការទាំងសងខាង ។ មានការអះអាងថា គឺមានឥទ្ធិពលបំផុត ហើយមានចីរភាពបំផុត នៅពេលដែលយន្តការទទួលខុសត្រូវសង្គម ត្រូវបានធ្វើស្ថាបនីយកម្ម (រៀបចំស្ថាប័ននានាទៅជារូបវន្តបុគ្គលឱ្យទទួលខុសត្រូវដាច់ដោយឡែក១) ឬនៅពេលដែលយន្តការទទួលខុសត្រូវសង្គម "ផ្ទៃក្នុង" របស់រដ្ឋផ្ទាល់ត្រឡប់មកមានតម្លាភាពឡើង ហើយបើកទូលាយឱ្យមានការចូលរួមខ្ជាប់ខ្ជួនពីប្រជាពលរដ្ឋ ។ ការធ្វើដូចនេះ គឺស្របទៅនឹងអ្នកប្រាជ្ញមួយចំនួន ដែលបានចាត់ថាមានការទទួលខុសត្រូវបែប "កាត់ទទឹង" , "កូនកាត់" ឬ "វិជ្ឈកោណ" (ដូចបន្ទាត់គូសពីជ្រុងមួយមកជ្រុងឈមមួយទៀត) ។

លក្ខណៈជាគន្លឹះមួយទៀត នៃយន្តការទទួលខុសត្រូវសង្គម គឺការប្រើទាំងកម្មវិធីរង្វាន់ ទាំងទណ្ឌកម្ម និង គំនាបជំរុញផង ទៅតាមលំដាប់លំដោយមួយ ។ យុទ្ធសាស្ត្រអនុវត្តជាក់ស្តែងអាស្រ័យលើកត្តាមួយចំនួនរួមទាំង : កត្តាធម្មជាតិ និងបំណងនៃដើមគំនិតទទួលខុសត្រូវសង្គម កត្តាអនុលោមភាព (ភាពស្របតាមគោលដៅ ឬដែនកំណត់) កត្តាកម្រិតជំនាញ និងមធ្យោបាយរបស់ជនដែលរកការទទួលខុសត្រូវ, និងកត្តាមធ្យោបាយ ដើម្បីធានាឱ្យមានការគោរពតាមជាផ្លូវការដែលអាចរកបាន ។ ជាធម្មតា យន្តការផ្តល់រង្វាន់លើកទឹកចិត្ត និង ដាក់ទណ្ឌកម្ម ក្រៅផ្លូវការអាស្រ័យលើការបង្កើតគំនាបជំរុញសាធារណៈ ឧទាហរណ៍តាមរយៈ

ការយកព័ត៌មានទៅផ្សព្វផ្សាយ (ទាំងព័ត៌មានវិជ្ជមាន ទាំងអវិជ្ជមាន) តំបន់ផ្សព្វផ្សាយ, ការបង្ហាញពីការគាំទ្រ ឬការតវ៉ាពីសាធារណៈ វេទិកាទូទៅរវាងប្រជាពលរដ្ឋ និងមន្ត្រីសាធារណៈ ដែលជួបគ្នាចំរុះ បដ្ឋនាលិខិត (លិខិតដែលចុះហត្ថលេខាដោយមនុស្សច្រើនជូនទៅអាជ្ញាធរ) ។ល។ នៅពេលចាំបាច់ ក្រុមប្រជាពលរដ្ឋអាចតវ៉ា សុំឱ្យវិនិច្ឆ័យសាជាថ្មីចំពោះរបៀបដាក់ទោសរបស់រដ្ឋ ឬរប្យបដាក់គំនាប ជំរុញការគោរព ដើម្បីឱ្យមានការផ្លាស់ប្តូរ ដូចជាតាមរយៈការបង្ហាញភស្តុតាង ដល់ភ្នាក់ងារត្រួតពិនិត្យ អំពើពុករលួយ, ការប្តឹងតវ៉ាទៅអ្នកស៊ើបអង្កេត មុខងារសាធារណៈរបស់រដ្ឋ ឬការធ្វើពាក្យបណ្តឹងទាមទារ តាមរយៈប្រព័ន្ធតុលាការ ។ ជាញឹកញយ ទោះជាយ៉ាងណាមធ្យោបាយទាំងនេះមិនមានឡើយ ឬគ្មានប្រសិទ្ធភាព ឬមានប្រសិទ្ធភាពតិចមិនអាចឱ្យមានការផ្លាស់ប្តូរ ពិតប្រាកដឡើយ ។ ក្នុងករណីទាំងនេះ សកម្មភាពរបស់ប្រជាពលរដ្ឋអាចនឹងបែរឆ្ពោះទៅរកការកែប្រែភាព មិនសមស្របនៃយន្តការទាំងនេះវិញ ឬបែរមកតវ៉ា បញ្ចុះបញ្ចូលឱ្យមានកំណែទម្រង់ (កែប្រព័ន្ធច្បាប់រដ្ឋបាល ឬស្ថាប័ន) ឬក៏បង្កើនប្រសិទ្ធភាពតវ៉ាកែប្រែ តាមរយៈប្រជាពលរដ្ឋខ្លួនឯងចូលរួមក្នុងសកម្មភាពសាធារណៈ ។ ម្យ៉ាងទៀត សកម្មភាពទាំងនេះ មានសក្តានុពល អាចនាំឱ្យមានយន្តការដាក់គំនាបជំរុញការគោរពបែបជំនាន់កូនកាត់ថ្មី (ដូចជាថ្មីបែបពាក់កណ្តាលផ្លូវការ) ឧទាហរណ៍ គណៈកម្មាធិការមើលការខុសត្រូវនៃប្រជាពលរដ្ឋ ឬ យន្តការដោះស្រាយសាទុក្ខ (ដែលមានកម្រិតផ្លូវការ និង អាជ្ញាធរច្បាប់ចូលក្នុងនោះកម្រិតផ្សេងៗ) ។

សកម្មភាព និង ឧបករណ៍ច្បាប់ជាច្រើនត្រូវបានប្រើដើម្បីសម្រេចបានគោលដៅទទួលខុសត្រូវសង្គម ។ ជាអាទិ៍ ផ្នែកទី ៣ នៃឯកសារនេះ មានការបែងចែកចាត់ថ្នាក់នូវឧបករណ៍ទទួលខុសត្រូវសង្គម ទៅតាមដំណាក់កាលនៃវដ្តក្នុងការតាក់តែងច្បាប់ ឬការធ្វើគម្រោងថវិកាជាដើម ដែលត្រូវប្រើឧបករណ៍ណាខ្លះនោះ ។ នៅពេលដែលបទពិសោធន៍កាន់តែកើននោះ មានការខិតខំអភិវឌ្ឍលក្ខខណ្ឌនានា ដើម្បីញែក និង ចាត់ថ្នាក់នូវឧបករណ៍ទទួលខុសត្រូវសង្គម ។ យន្តការទទួលខុសត្រូវសង្គមទាំងឡាយ អាចត្រូវបានញែកជា ឧទាហរណ៍ ទៅតាម (១)ថាតើវាចេញពីគំនិតផ្តួចផ្តើមរបស់ប្រជាពលរដ្ឋ ឬ ដោយរដ្ឋ (២)វិសាលភាពប្រើជាលក្ខណៈ "ស្ថាបនីយកម្ម" ឬ "ឯករាជ្យ" (៣)វិសាលភាពប្រើជាលក្ខណៈ "សហការ" ឬក៏ "ជំទាស់" (៤)ថាតើប្រើការដាក់ទណ្ឌកម្មផ្លូវការ ឬ ក្រៅផ្លូវការ និង (៥)ថាតើវាផុសឡើងនៅមូលដ្ឋាន តំបន់ ឬ នៅថ្នាក់ជាតិ ។ល។

## ហេតុអ្វីការទទួលខុសត្រូវសង្គមមានសារៈសំខាន់?

មានការយល់ឃើញធំៗ ៣ ដែលបង្ហាញពីសារៈសំខាន់នៃការទទួលខុសត្រូវសង្គមគឺ **ធ្វើឱ្យរីកចម្រើនអភិបាលកិច្ច បង្កើនប្រសិទ្ធភាព ការអភិវឌ្ឍ និងការផ្តល់អំណាច** ។ ចំណុចនីមួយៗនឹងលើកមកពិភាក្សានៅខាងក្រោម ។

ជាបឋម បញ្ហាអភិបាលកិច្ច ការទទួលខុសត្រូវរបស់មន្ត្រីសាធារណៈជាចំណុចសំខាន់របស់រដ្ឋាភិបាល និងតម្រូវការបឋមឱ្យមានលទ្ធិប្រជាធិប្បតេយ្យដែលមានប្រសិទ្ធភាព ។ សព្វថ្ងៃនេះនៅពេលមានការយល់ដឹងពីសិទ្ធិនិងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋកំពុងកើនឡើង និង រីកដុះដាលនោះ ទំនាក់ទំនងរវាងប្រជាពលរដ្ឋ ហើយរដ្ឋាភិបាលរបស់គេទទួលស្គាល់ដោយអ្វីដែលគេហៅថា "វិប្បត្តិច្បាប់" (សៀវភៅការវន្ដា ២០០២) គ្រាន់តែជា " វិបត្តិរដ្ឋាភិបាល " (ប៉ូល ២០០២) ។ ប្រជាពលរដ្ឋទាំងខាងជើង និង ខាងត្បូងសម្តែងចេញការ បាត់បង់ជំនឿរបស់គេ ជាមួយនឹងរដ្ឋាភិបាល និងលើកឡើងនូវកង្វះខាតការឆ្លើយតប ការបិទបាំង អំពើពុករលួយ ការនិយមបក្សពួក និង ការទទួលខុសត្រូវសង្គមមិនល្អរបស់មន្ត្រីសាធារណៈ និង អ្នកការិយាធិបតេយ្យ (មូលនិធិឯករាជមួយ១៩៩៩ នារាយាន ២០០០) ។ ជាពិសេសក្នុងបរិបទនៃប្រទេសកំពុងអភិវឌ្ឍ ប្រសិទ្ធភាពនៃយន្តការទទួលខុសត្រូវជាទូទៅ បានបង្ហាញថា នៅមានកម្រិត ។ ដូចបានពិភាក្សាខាងលើការបោះឆ្នោតយន្តការទទួលខុសត្រូវ " ផ្តេក" បានបង្ហាញពីឧបករណ៏អន់ និងចំពេលកាន់តំណែង របស់មន្ត្រីរដ្ឋាភិបាល និងនិយោជិកទទួលខុសត្រូវចំពោះសកម្មភាព ។ យន្តការទទួលខុសត្រូវធ្វើឱ្យប្រជាពលរដ្ឋធម្មតាអាចទទួលព័តិមានបានបញ្ចេញសំឡេងតម្រូវការរបស់គេបាន និង ទាមទារឱ្យមានការទទួលខុសត្រូវក្នុងការបោះឆ្នោត ។ ការធ្វើឱ្យមានការទទួលខុសត្រូវសង្គមកើតឡើង ជំរុញឱ្យមាន សមត្ថភាពរបស់ប្រជាពលរដ្ឋ ដើម្បីឈានទៅមុខប្រសើរ ជាងគ្រាន់តែប្រឆាំងតវ៉ាចំពោះការពាក់ពន្ធ័ជាមួយនឹងអ្នកការិយាធិបតេយ្យ និង អ្នកនយោបាយនៅក្នុងលក្ខខណ្ឌ ដែលធ្វើបានត្រឹមត្រូវក្នុងវ័យស្លាបនារបស់ខ្លួនជាប្រជាពលរដ្ឋ និង ការបង្កើនឱ្យមានឱកាសធ្វើការផ្លាស់ប្តូរវិជ្ជមាន។

ការទទួលខុសត្រូវសង្គមក៏អាចនាំឱ្យមានការបង្កើនប្រសិទ្ធភាពអភិវឌ្ឍន៏ ។ គេអាចសម្រេចបានតាមរយៈបង្កើនការផ្តល់សេវាសាធារណៈ និង ការរៀបចំគោលនយោបាយ ។ នៅក្នុងប្រទេសជាច្រើន ជាពិសេសតែប្រទេសកំពុងអភិវឌ្ឍន៏ រដ្ឋាភិបាលមិនអាចបញ្ជូនសេវាសំខាន់ៗទៅឱ្យប្រជាពលរដ្ឋរបស់ខ្លួន ដោយសារតែបញ្ហាដែលមានដូចជា : -ការប្រើធនធានមិនបានត្រឹមត្រូវ -ការលេចឮថាមានអំពើពុករលួយ -គ្រឿងលើកទឹកចិត្តខ្សោយ ឬដំណើរមិនមានការទាមទារ នោះទេ ។ ស្រដៀងគ្នានេះដែរ រដ្ឋាភិបាលជាច្រើនតែងតែបង្កើតគោលនយោបាយលាក់កំបាំង និងគ្មានតម្លាភាពដែលផ្ទុយទៅនឹងចំណាប់អារម្មណ៏ និង បញ្ហាអាទិភាពជាក់ស្តែងរបស់ជនក្រីក្រ ។ បញ្ហាទាំងនេះត្រូវស្ថិតនៅអូសបន្លាយ ដោយសារតែក្រុមអ្នកដើរតួសំខាន់ទាំងបី ដែលស្ថិត

នៅក្នុងចំណោម ▪ *អ្នកធ្វើគោលនយោបាយសាធារណៈនិងអ្នកបង្កើតគោលនយោបាយផ្តល់សេវាបន្ត* ▪ *អ្នកផ្តល់សេវា* និង ▪ *ប្រជាពលរដ្ឋ* មានគោលដៅ និង វិធីលើកទឹកចិត្តខុសៗគ្នា (ជួនកាលឈានដល់ជម្លោះ) រួមមានទាំងព័ត៌មានមិនល្អជាមួយគ្នា និង ការខ្វះខាតការប្រាស្រ័យទាក់ទងជាមួយគ្នា ។ តាមរយៈព័ត៌មាន និង ការពង្រឹងឱ្យមានការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ ការជំរុញឱ្យមានការពិភាក្សា និង ការប្រជុំរវាងក្រុមអ្នកដើរតួសំខាន់ទាំងបី នឹង បង្កើតឱ្យមានវិធីលើកទឹកចិត្តចំពោះទង្វើប្រសើរណាមួយ ។ យន្តការទទួលខុសត្រូវសង្គមអាចរីករាលដាលចំពោះការបង្កើនឱ្យមានប្រសិទ្ធភាពពីការបញ្ជូនសេវា និង ធ្វើការសម្រេចចិត្តឱ្យកាន់តែមានតម្លាភាព មានការចូលរួម និងមានការគាំទ្រពីជនក្រីក្រ ។ចាប់តាំងពីជនក្រីក្រកាន់តែពឹងផ្អែកលើសេវារដ្ឋាភិបាលមក ហើយមន្ត្រីរដ្ឋាភិបាលកាន់តែមានសម្ភារបរិក្ខារតិចតួចបំផុតៗទៅ សម្រាប់ការទទួលខុសត្រូវនោះ ជនក្រីក្រទាំងនោះ ត្រូវតែទទួលឱ្យបានប្រសើរនូវការផ្តួចផ្តើមគំនិតស្តីពីការទទួលខុសត្រូវសង្គម ។

នៅចុងក្រោយការ**ផ្តួចផ្តើមគំនិត**ទទួលខុសត្រូវសង្គម អាចនាំឱ្យមានការផ្តល់អំណាចពិសេសដល់ជនក្រីក្រ ។ នៅពេលគ្មាននិយមន័យណាមួយ របស់ពាក្យផ្តល់អំណាច យ៉ាងហោចណាស់ ក៏គេអាចយល់វាថា ជា**ការពង្រីកសេរីភាពក្នុងការជ្រើសរើសនិងការធ្វើសកម្មភាព** ។ ការស្រាវជ្រាវមួយបានបង្ហាញថា ការមិនសប្បាយចិត្តរបស់ជនក្រីក្រ ចំពោះរដ្ឋាភិបាល ទាក់ទងខ្លាំងជាមួយនឹងបញ្ហាការ ឆ្លើយតបនិងការទទួលខុសត្រូវ ។ ជនក្រីក្របានរាយការណ៍ថា វិទ្យាស្ថានរដ្ឋ គឺតែងតែមិនឆ្លើយតប និង មិនទទួលខុសត្រូវចំពោះជនក្រីក្រទេ និងមិនទទួលខុសត្រូវចំពោះនរណាមួយ ឬ ទទួលខុសត្រូវចំពោះតែអ្នកមាន និងអ្នកមានអំណាច (ណារ៉ាយ៉ាន ២០០០ទំព័រ១៧២ និង ១៧៧) ។ នៅមានព័ត៌មានរិះគិតពីសិទ្ធិ និង ការតែងតាំង និង ការរើសយកចម្លើយតប ជាប្រព័ន្ធពីជនក្រីក្រ យន្តការទទួលខុសត្រូវសង្គមមានវិធីបង្កើតសំឡេងរួមរបស់ក្រុមអ្នកមិនទទួលបានផលប្រយោជន៍ និង ទទួលរងគ្រោះពីសង្គម ។ សំឡេងរួមទាំងនេះបានឱ្យអំណាចដល់ជនក្រីក្រ និង បង្កើនឱកាសដល់ការឆ្លើយតបកាន់តែខ្លាំងពីតម្រូវការរបស់គេ ។ វាមានន័យថា វាអាចឈានដល់ដៃរបស់ប្រជាពលរដ្ឋក្រីក្រហើយ ជំនួយដែលគេតម្រូវឱ្យផ្តួចផ្តើមគំនិតអំពីសកម្មភាពទទួលខុសត្រូវសង្គមរបស់គេផ្ទាល់ នឹងធានាថា យន្តការទទួលខុសត្រូវសង្គមត្រូវតែរៀបចំជាផលប្រយោជន៍ដល់ជនក្រីក្រ (និងមិនសង្កត់សង្កិនដោយអ្នកមានអំណាច) និងជាការប្រកួតប្រជែងយ៉ាងសំខាន់ពីការទទួលខុសត្រូវប្រកបដោយ ប្រសិទ្ធភាព និង មានការគាំទ្រពីសង្គមនៃជនក្រីក្រ។

រូបទី ១ : ហេតុអ្វីបានការទទួលខុសត្រូវសង្គមមានសារៈសំខាន់?




**ទំនាក់ទំនងរវាងការទទួលខុសត្រូវសង្គម និង ទស្សនៈសំខាន់ /របៀបវារៈផ្សេងៗទៀត**

ការយល់ដឹងពីការទទួលខុសត្រូវសង្គមមានទំនាក់ទំនងទៅនឹងទស្សនៈសំខាន់មួយចំនួនទៀត និង របៀបវារៈនានា ។ ដូចបានរៀបរាប់ខាងលើមកហើយ យន្តការទទួលខុសត្រូវសង្គមមានតួនាទីសំខាន់ក្នុងការធ្វើឱ្យអភិបាលកិច្ចបានល្អប្រសើរ និង ធ្វើឱ្យលទ្ធិប្រជាធិបតេយ្យកាន់តែស៊ីជម្រៅថែមទៀត ។ ការទទួលខុសត្រូវសង្គមជួន កាលសំដៅលើអ្វីដែលជាការទាមទារឱ្យមានអភិបាលកិច្ចល្អ ដោយសារតែវាផ្អែកលើការចូលរួមយ៉ាងសកម្មពីប្រជាពលរដ្ឋ ដើម្បីទទួលយកការទទួលខុសត្រូវពីអ្នកតំណាង និង អ្នកដឹកនាំដែលគេបោះឆ្នោតឱ្យ ។

ការទទួលខុសត្រូវសង្គមក៏អាចជាសក្តានុពលយ៉ាងខ្លាំង ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រតាមរយៈការរៀបចំគោលនយោបាយដែលមានការគាំទ្រពីប្រជាពលរដ្ឋក្រីក្រ និង ធ្វើឱ្យសេវាកម្មបញ្ជូន និង ការផ្តល់អំណាចកាន់តែប្រសើរឡើង ។ យន្តការទទួលខុសត្រូវសង្គមខ្លះទៀតត្រូវបានគេបង្កើតឡើងយ៉ាងច្បាស់លាស់ ដើម្បីជាប្រយោជន៍ ដល់ជនក្រីក្រ (ដូចជាសុខាភិបាលសាធារណៈ ការអប់រំ ទឹកនិងសេវាអនាម័យផ្សេងទៀត)។ យ៉ាងណាក៏ដោយ ដូចបានរៀបរាប់ខាងលើអញ្ចឹង ការខិតខំឥតឈប់ឈរត្រូវធានាថាការផ្តួចផ្តើមគំនិតទទួលខុសត្រូវសង្គម បាន បម្រើតម្រូវការអាទិភាពរបស់ជនក្រីក្រយ៉ាងមានប្រសិទ្ធភាព រួមបញ្ចូលទាំងយន្តការយកឈ្នះឧបសគ្គដែលមាន សក្តានុពលចំពោះការចូលរួមរបស់គេដោយប្រសិទ្ធភាព និង ធ្វើឱ្យជនក្រីក្រ ស្ថិតនៅទីមានសុវត្ថិភាពផងដែរ។

ការទទួលខុសត្រូវសង្គម ក៏ អាចមានការទទួលខុសត្រូវផ្នែកយេនឌ័រដ៏សំខាន់ដែរ។ ស្ត្រីមិនត្រូវបានលើកមកនិយាយគ្រប់កម្រិត នៅតាមស្ថាប័នរដ្ឋាភិបាលសឹងគ្រប់ប្រទេសលើពិភពលោក ។ ស្ថានភាពនយោបាយនេះធ្វើឱ្យសមត្ថភាពស្ត្រីចុះខ្សោយ ហើយត្រូវតែជំរុញឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ និង ការពារសិទ្ធិរបស់ពួកគេ។ ដោយសារតែដំណើរការទៅមុខ និង ចរិតខំប្រឹងប្រែងទាមទារទាំងនេះហើយ បានជាយន្តការទទួលខុសត្រូវសង្គមជំរុញឱ្យស្ត្រីមានសមត្ថភាពបញ្ចេញសំឡេងរបស់គេឡើង ។ ឧបករណ៍ទទួលខុសត្រូវមួយចំនួន (ដូចជាការ

ធ្វើថវិកាយេនឌ័រ និង ការត្រួតពិនិត្យតាមដាននិងវាយតម្លៃដោយមានការចូលរួមផ្សេងគ្នាខាងយេនឌ័រ) ត្រូវបានគេរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាយេនឌ័រនេះ ។ ដូចបានរៀវរាប់នៅក្នុងកថាខណ្ឌខាងលើមកហើយថាការផ្តួចផ្តើមគំនិតទទួលខុសត្រូវសង្គម តែងតែមានគោលដៅចំពោះផ្នែកសាធារណៈទាំងនោះ ដែលមានសារៈសំខាន់បំផុតដល់ជនក្រីក្រ ដែលក្នុងនោះ ស្ត្រីជាផ្នែកមួយដ៏សំខាន់បំផុត។ ស្រដៀងគ្នានេះដែរ ការផ្តួចផ្តើមគំនិតទទួលខុសត្រូវសង្គមមានសក្តានុពលយ៉ាងខ្លាំង និង ត្រូវបានគេចាប់អារម្មណ៍ ចំពោះសេចក្តីត្រូវការពីក្រុមនេះក្នុងសង្គម ថាតើជនពិការ កុមារ ឬ ជាយុវតី ។ តាមការផ្តោតអារម្មណ៍ពីស្ថានការណ៍លំបាករបស់កុមាររបាយការណ៍ដោយអង្គការសង្គមស៊ីវិលទូទាំងពិភពលោកបានឱ្យដឹងថា អនុសញ្ញាស្តីពីសិទ្ធិកុមារមានមូលដ្ឋានជាចម្បងសម្រាប់ថវិកាកុមារ និង គោលនយោបាយនានាដែលមានទំនាក់ទំនងគ្នា ។

យោងទៅតាមទ្រឹស្តីនយោបាយបានឱ្យដឹងថា តួនាទីសំខាន់របស់សង្គមស៊ីវិល គឺត្រូវឱ្យរដ្ឋាភិបាលទទួលខុសត្រូវ ។ តាមពិតទៅការទទួលខុសត្រូវរបស់សង្គម ជាតួនាទីយ៉ាងសំខាន់របស់សង្គមស៊ីវិល ។ ការទទួលខុសត្រូវសង្គមអាចយល់ផងដែរថាជាទម្រង់ពិសេសនៃការចូលរួមទទួលខុសត្រូវ ជាវិធីមួយ ដែលក្នុងនោះប្រជាពលរដ្ឋចូលរួមជាមួយរដ្ឋ ដើម្បី នាំមន្ត្រីសាធារណៈឱ្យទទួលខុសត្រូវ។ ទស្សនៈនៃការទទួលខុសត្រូវនេះជាប់ទាក់ទង ដូចគ្នាទៅនឹងការយល់ដឹង របស់ប្រជាពលរដ្ឋ ដែលសង្កត់បន្ថែមទៅលើសិទ្ធិ តួនាទី និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ និង ធ្វើឱ្យគេចូលរួម ព្រមទាំងមានការរំពឹងកាន់តែខ្លាំងឡើង ។

ការទទួលខុសត្រូវសង្គមទាក់ទងជិតស្និទ្ធទៅនឹងវិធីសាស្ត្រអភិវឌ្ឍផ្អែកលើសិទ្ធិ ។ កាតព្វកិច្ចរបស់មន្ត្រីរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ ចេញពីការយល់ដឹងសិទ្ធិនិងព័ត៌មានដែលតែងតែដាក់នៅក្នុងរដ្ឋធម្មនុញ្ញ និង ច្បាប់សិទ្ធិមនុស្ស ។ ការទទួលខុសត្រូវសង្គម បានផ្តល់ឱ្យយន្តការត្រួតពិនិត្យ និងការពារសិទ្ធិទាំងនេះ ។ ទស្សនៈនៃការទទួលខុសត្រូវសង្គមស្ថិតនៅលើសិទ្ធិរបស់ប្រជាពលរដ្ឋ ដើម្បីរំពឹងទុក និងធានាឱ្យរដ្ឋាភិបាលប្រព្រឹត្ត ដើម្បីផលប្រយោជណ៍ដល់ប្រជាពលរដ្ឋ ។

ទស្សនៈពីការទទួលខុសត្រូវសង្គមទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងការចូលរួមរបស់ពួកគេ ។ ការចូលរួមរបស់ប្រជាពលរដ្ឋចង្អុលបង្ហាញការទទួលខុសត្រូវសង្គមពីយន្តការអនុសញ្ញាស្តីពីការទទួលខុសត្រូវ ។ ក្នុងករណីជាច្រើន ប្រជាពលរដ្ឋសហគមន៍ និងអង្គការសង្គមស៊ីវិលមូលដ្ឋាន មិនត្រឹមតែចូលរួមក្នុងសកម្មភាពទទួលខុសត្រូវសង្គមប៉ុណ្ណោះទេថែមទាំងផ្តើមគំនិតពិនិត្យមើលពួកគេផងដែរ ។ យន្តការនៃការទទួលខុសត្រូវសង្គមអាចពង្រីកឱកាសឱ្យមានការចូលរួមពីគ្រប់កម្រិត នៃភាគីជាច្រើនទៀត ចំពោះសហគមន៍ខ្លួន នៅខណៈដែលមានដំណើរគិតគូរចូលជួយដាច់មួយតែឯង ឬជួយក្នុងកម្រិតតូចតាចណាមួយនោះ ។ នេះអាចរួមបញ្ចូលទាំងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការវិភាគ និង ការបង្កើតរូបមន្តថវិកាជាតិ និង ថវិកាតំបន់ ឬ ធ្វើឱ្យមានការ

រកឃើញការអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃ ដោយមានការចូលរួមពីកម្រិតទាបមានទំនាក់ទំនងគ្នាចំពោះបញ្ហាថវិកា រដ្ឋបាល និងអភិបាលកិច្ចនៅកម្រិតខ្ពស់របស់បណ្តាញចែកចាយសេវាសាធារណៈ ។

តាមរយៈការអនុវត្តការត្រួតពិនិត្យរបស់រដ្ឋាភិបាល ដែលទាមទារនិងជំរុញឱ្យមានតម្លាភាព ព្រមទាំងបង្ហាញឱ្យឃើញកំហុសស្តីពីបរាជ័យរបស់រដ្ឋាភិបាលនោះ យន្តការទទួលខុសត្រូវសង្គមជាឧបករណ៏ដ៏មានអំណាចទៅលើអំពើពុករលួយ ។ តាមពិត មានការនិយាយជជែកពីបណ្តាអ្នកខ្លះ ថាគ្រាន់តែជាការការពារច្បាស់ៗប្រឆាំងនឹងអំពើពុករលួយទៅនឹងផ្នែកសាធារណៈ ដែលគឺជាការត្រួតពិនិត្យមើលសង្គម ដែលកំពុងកើតឡើងយ៉ាងសកម្មក្នុងសកម្មភាពរបស់រដ្ឋាភិបាល ហើយកិច្ចការនោះមានការវិវត្តន៍ បើកចំហខ្លាំង ដោយមានការចូលរួមពីបណ្តាស្ថាប័នប្រឆាំងអំពើពុករលួយនានា។

យន្តការទទួលខុសត្រូវសង្គមអាចកោតសរសើរកំណែទម្រង់វិស័យសាធាណៈ តាមរយៈការដោះស្រាយចំណុចដែលទាមទារនូវការផ្គត់ផ្គង់សេវាសាធារណៈ ការត្រួតពិនិត្យ និង ការទទួលខុសត្រូវ ។ យន្តការទទួលខុសត្រូវសង្គមបានបង្ហាញសារៈប្រយោជន៍ក្នុងបរិបទវិមជ្ឈការ ដើម្បីជួយពង្រឹងទំនាក់ទំនងរវាង ប្រជាពលរដ្ឋ និងរដ្ឋាភិបាលកម្រិតមូលដ្ឋាន និង ជួយអាជ្ញាធរមូលដ្ឋាន និង អ្នកផ្តល់សេវា ឱ្យកាន់តែមានការឆ្លើយតប និងកាន់តែមានប្រសិទ្ធភាព។

## គ. ការទទួលខុសត្រូវសង្គម : ការកសាងក្រុម

ដូចបានរៀបរាប់ខាងលើមកហើយថាការទទួលខុសត្រូវសង្គមរួមទាំងទំហំសមត្ថភាពយ៉ាងច្រើន ដែលប្រជាពលរដ្ឋអាចធ្វើឱ្យមន្ត្រីរដ្ឋាភិបាល និង អ្នកការិយាធិបតេយ្យទទួលខុសត្រូវ ។ សមត្ថភាពទាំងនេះអាចត្រូវអនុវត្តដោយក្រុមមួយចំនួន ដូចជាប្រជាពលរដ្ឋម្នាក់ៗ សហគមន៍ សមាជិកសភា អង្គការសង្គមស៊ីវិល បណ្តាញព័ត៌មាន ដែលធ្វើការនៅកម្រិតខុសគ្នា (ដូចជា តាំងពីថ្នាក់មូលដ្ឋានដល់ ថ្នាក់ជាតិ) ដើម្បីដោះស្រាយបញ្ហាផ្សេងគ្នាជាច្រើន (ដូចជាគោលនយោបាយ ការអនុវត្តនយោបាយ ប្រាក់ចំណាយសាធារណៈ ការផ្តល់សេវា) និងប្រើប្រាស់យុទ្ធសាស្ត្រផ្សេងគ្នា (ដូចជា ការស្រាវជ្រាវ ការត្រួតពិនិត្យ ផែនការដោយមានការចូលរួម ការអប់រំទំហំនៃការផ្សព្វផ្សាយព័ត៌មាន ការកសាងក្រុម) ។ បើទោះជាមានភាពចំរុះគ្នាដូចនេះក៏ដោយ ក៏ការទទួលខុសត្រូវសង្គម ឈានដល់ដំណើរការពិសេសច្បាស់លាស់ក្នុងការសម្តែងចេញផលប្រយោជន៍រួមគ្នានឹងការចរចា ។ លើសពីការតស៊ូមតិ គេតែងតែព្យាយាមបង្កើតមូលដ្ឋានជាក់ស្តែងដែលគួរឱ្យចាប់អារម្មណ៏មួយ ចំពោះការចូលរួមរបស់សាធារណៈ ។ វាតែងតែផ្សំពីធាតុសំខាន់ជាច្រើនដូចខាងក្រោមនេះ (និងបើតាមគិតទាំងអស់) ឬ "បង្កើតក្រុម" ។

## ការកៀងគរជុំវិញចំណុចមាត់ច្រកចូល

ជំហានដំបូងនៃការទទួលខុសត្រូវសង្គមគឺការកំណត់អត្តសញ្ញាណនៃចំណុចចូល និង ការអភិវឌ្ឍយុទ្ធសាស្ត្រ ដែលបញ្ហាអាទិភាពអាចត្រូវគេដោះស្រាយបាន ។ បញ្ហាអាចមានលក្ខណៈពិសេស ឬ ទូទៅ និងអាចត្រូវគេឱ្យអត្តសញ្ញាណគ្រប់កម្រិត ។ ឧទាហរណ៍ដូចជាករណីពីការផ្តល់សេវាសុខភាពមិនល្អ ជាមាត់ច្រកចូលដ៏មានសក្តានុពល អាចរួមមានការចាយវាយថវិកាសុខាភិបាលជាតិ អំពើពុករលួយអំពីប្រសិទ្ធភាពនៅក្នុងប្រព័ន្ធចែកចាយរបស់ជាតិ ឬការបំពេញការងាររបស់អ្នកផ្តល់សេវាតាមតំបន់ ឬគណៈកម្មាធិការគ្រប់គ្រងសុខាភិបាលតាមភូមិ ។ ពួកគេនីមួយៗអាចចង្អៀតចង្អល់ ខ្លាំងចំពោះការផ្តល់សេវាសុខភាព។ យុទ្ធសាស្ត្រដ៏មានសក្តានុពលដើម្បីដោះស្រាយបញ្ហាទាំងនោះអាចរួមមានដូចជា ការវិភាគថវិកា សមត្ថភាពតស៊ូមតិ ការតាមដានធនធានសុខាភិបាល និងការចំណាយ ការវាយតម្លៃ ដោយមានការចូលរួមពីសេវាសុខភាពតាមតំបន់ ។ល។...

## ការបង្កើតព័ត៌មាន និង មូលដ្ឋានភស្តុតាង

ការទទួលបាន ប ការបង្កើតព័ត៌មានទាក់ទិនគ្នានិងការបង្កើតមូលដ្ឋានភស្តុតាង ដែលអាចជឿបាន និងធ្វើឱ្យមន្ត្រីសាធារណៈទទួលខុសត្រូវចំពោះចំណុចដែលត្រូវទទួលខុសត្រូវសង្គម ។ ការផ្តួចផ្តើមគំនិតទទួលខុសត្រូវ តែងតែទាក់ទងនឹងការទទួលយក

:(១) ទិន្នន័យ/ព័ត៌មានផ្តល់ឱ្យ(ពីរដ្ឋាភិបាលនិងអ្នកផ្តល់សេវា) និង

(២) ទិន្នន័យ/ព័ត៌មានទាមទារ(ពីអ្នកប្រើប្រាស់សេវារបស់រដ្ឋាភិបាល សហគមន៍ និង ប្រជាពលរដ្ឋ)

ក្នុងការបើប្រាស់ព័ត៌មានផ្តល់ឱ្យ (ដូចជាសេចក្តីថ្លែងការណ៍គោលនយោបាយនៃការប្រើប្រាស់ថវិកា និងគណនី ការកត់ត្រាធនធាន លទ្ធផល និង ប្រាក់ចំណាយ ការរកឃើញរបស់សវនករ ។ល។...) តម្លាភាពរបស់រដ្ឋាភិបាលនិងសមត្ថភាពរបស់ខ្លួនដើម្បីផលិតនិងចែកចាយទិន្នន័យនិងគណនី ជារឿងសំខាន់ ។ ចំពោះព័ត៌មានទាមទារ វិធីសាស្ត្រ និង ឧបករណ៍ ដែលមានការចូលរួមផ្សេងគ្នា (ដូចជា ពិសហគមន៍ របាយការណ៍ប្រជាពលរដ្ឋ បច្ចេកទេសពីការត្រួតពិនិត្យនិងវាយតម្លៃដោយមានការចូលរួម) ត្រូវបានគេធ្វើដើម្បីបង្កើតទិន្នន័យ នៅពេលដែលគេប្រើវាសម្រាប់ពញ្ញាក់អារម្មណ៍ និង ជំរុញឱ្យមានការរៀបចំអង្គការតាមតំបន់។

នៅពេលយើងបានទទួលព័ត៌មាន និង ទិន្នន័យទាក់ទិនគ្នាហើយ វាត្រូវគេបកស្រាយ និង វិភាគ ដើម្បីយកមកប្រើប្រាស់ឱ្យមានសារៈប្រយោជន៍ ។ ធ្វើដូច្នេះត្រូវធ្វើការងារជាមួយអ្នកជំនាញ ដែលបានទទួលការអប់រំ (ដូចជា អ្នកណាអាចជួយធ្វើឱ្យថវិកាកាន់តែងាយយល់ ឬចែកលម្អិតគណនីហិរញ្ញវត្ថុ) ឬប្រើវិធីចូលរួម ដើម្បីជួយសមាជិកសហគមន៍ ឬ ក្រុមអ្នកប្រើប្រាស់ វិភាគទិន្នន័យតាមតំបន់ ឬវាយតម្លៃសេវាសាធារណៈរួម ។ ក្នុងករណីណាមួយ ក៏ដោយ គោលបំណងនៃការវិភាគ គឺត្រូវបង្កើតការរកឃើញន័យគ្រប់គ្រាន់ ដែលអ្នកពាក់ព័ន្ធទាំងអស់អាចយល់បាន និង លើសពីនេះប្រើដើម្បីទប់ទល់ចំពោះការពិភាក្សាផ្អែកលើភស្តុតាង ។

## ផ្សព្វផ្សាយជាសាធារណៈ

ការយកព័ត៌មាន និង ការរកឃើញទៅលាតត្រដាងជាសាធារណៈ និង បង្កើតការពិភាក្សាសាធារណៈជុំវិញបញ្ហាទាំងនោះ គឺជាគន្លឹះមួយចំពោះការចាប់ផ្ដើមឱ្យមានការទទួលខុសត្រូវសង្គម ។ ផែនការថវិកាត្រូវតែបរិយាយឱ្យបានល្អិត និង រកឃើញប្រាក់ចំណាយសាធារណៈ សវនកម្ម ឬលទ្ធផលពីការវាយតម្លៃគម្រោង ។ ព័ត៌មាននេះអាស្រ័យលើសារៈសំខាន់ និង ឥទ្ធិពលថ្មី នៅពេលដែលសាធារណៈជនដឹង និង បម្រើទាំងព័ត៌មាន និងជំរុញកម្លាំងឱ្យមានសកម្មភាព ។ យុទ្ធសាស្ត្រទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និង យន្តការគឺជាចំណុចសំខាន់សម្រាប់ការទទួលខុស ត្រូវសង្គម ។ នេះអាចរួមទាំងការរៀបចំការប្រជុំ និង ព្រត្តិការណ៍សាធារណៈ ព្រមទាំងការប្រើប្រាស់យុទ្ធសាស្ត្រពីការបង្កើតបណ្ដាញទាន់សម័យ និង បុរាណ ។ ការផ្សព្វផ្សាយព័ត៌មាននេះទៅកាន់មន្ត្រីរដ្ឋាភិបាល ដែលមានតួនាទី (និងផ្សព្វផ្សាយផ្ទាល់ជាមួយអ្នកធ្វើការសម្រេចចិត្តជាមូលដ្ឋានដែលកើតមានឡើង) គឺជាចំណុចសំខាន់នៃការទទួលខុសត្រូវសង្គម ។

## ប្រមូលផ្ដុំការគាំទ្រ និង កសាងកម្លាំងចំរុះ

ប្រជាពលរដ្ឋដែលដឹងពីសិទ្ធិ និង ការទទួលខុសត្រូវចូលរួមពីផលប្រយោជន៍របស់គេ និង ប្រមូលគ្នាដើម្បីបង្កើតកម្លាំងចំរុះ និង បង្កើតភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធដទៃទៀត( ដូចជាអ្នកការិយាធិបតេយ្យ បណ្ដាញព័ត៌មាន អ្នកតំណាងរាស្ត្រ ។ល ។...) ទៅជាចំណុចសំខាន់នៃការទទួលខុសត្រូវសង្គម ។ គ្រប់ជំហាននៃការចាប់ផ្ដើមទទួលខុសត្រូវសង្គមបានចូលរួមចែកព័ត៌មានដល់ប្រជាពលរដ្ឋ និងកៀងគរការគាំទ្រ ។ ភាពប៉ិនប្រសប់របស់ប្រជាពលរដ្ឋ គឺត្រូវរៀបចំឱ្យមានសកម្មភាពរួម ហើយសមត្ថភាពរបស់អង្គការសង្គមស៊ីវិល គឺត្រូវសម្របសម្រួល និងគាំទ្រការប្រមលផ្ដុំ ដែលធ្វើបែបនេះគឺជាចំណុចសំខាន់ ដើម្បីជោគជ័យដល់ការចាប់ផ្ដើមទទួលខុសត្រូវសង្គម ។ ជាថ្មីម្ដងទៀតការទៅជួបប្រជាពលរដ្ឋក្រីក្រ និងក្រុមជនភាគតិច តម្រូវឱ្យមានការខិតខំប្រឹងប្រែង និងមានការប្រកួតប្រជែង ។

**រូបទី២ : ការបង្កើតក្រុម ដែលមានការទទួលខុសត្រូវសង្គម**




**ការតស៊ូមតិ និង ការចរចាឱ្យមានការផ្លាស់ប្តូរ**

ធាតុដ៏សំខាន់បំផុត និងមានការប្រកួតប្រជែងនៃយុទ្ធសាស្ត្រទទួលខុសត្រូវសង្គមគឺមិនអាចជ្រើសរើសចម្លើយតបពីមន្ត្រីសាធារណៈ និង ការកែប្រែពិតប្រាកដ ។ យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពបំផុតតែងតែមានទំនាក់ទំនងផ្ទាល់នឹងការចរចាជាមួយដៃគូមន្ត្រីរដ្ឋាភិបាល និង យន្តការ ដើម្បីឱ្យមានការពិភាក្សានិងប្រឹក្សាបានកើតឡើង ។ ដូចបានពិភាក្សាខាងលើមកហើយក្នុងការចរចា ឱ្យមានការផ្លាស់ប្តូរ ក្រុមប្រជាពលរដ្ឋប្រើមធ្យោបាយផ្លូវការ និង ក្រៅផ្លូវការពីការប៉ះពាល់ការកៀបសង្កត់ ការឱ្យរង្វាន់និងការដាក់ទណ្ឌកម្ម ។ នេះរួមទាំងការបង្កើតឱ្យមានការកៀប សង្កត់សាធារណៈ (ដូចជាតាមរយៈយុទ្ធនាការ ព័ត៌មាន និង ការប្រជុំសាធារណៈ) ឬនៅពេលចាំបាច់ដោយត្រឡប់មកប្រើប្រាស់មធ្យោបាយផ្លូវការណ៍ នៃការបញ្ជាក់ប្រាប់ (ដូចជាតាមរយៈច្បាប់ និង ដំណើរការច្បាប់) ។ ឱកាសសម្រាប់ការចរចា ព្រមទាំងការដែលអាចតវ៉ាឱ្យមានវិធីដាក់ទណ្ឌកម្មផ្លូវការឱ្យខ្លាំងពីបរិបទប្រទេសមួយទៅ បរិបទប្រទេសមួយទៀត ។ នៅក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើនក្រុមប្រជាពលរដ្ឋបានឃើញកំណែទម្រង់ច្បាប់ស្ថាប័ន ចាំបាច់ដើម្បីសម្របសម្រួលការចរចាប្រកបដោយអត្ថន័យ ។

## ឃ.ការទទួលខុសត្រូវសង្គម : ការអនុវត្ត និង ឧបករណ៍ប្រើប្រាស់

ប្រភេទយុទ្ធសាស្ត្រ និងវិធីសាស្ត្រមួយចំនួន (រួមបញ្ចូលទាំងធាតុសំខាន់មួយចំនួនឬទាំងអស់ដែលរៀបរាប់ខាងលើ) ត្រូវបង្កើតឡើងដើម្បីជំរុញឱ្យមានការទទួលខុសត្រូវសង្គម ។ នៅក្នុងបរិបទរបស់ធានាគារពិភពលោក មានការគាំទ្រឱ្យមានការទទួលខុសត្រូវសង្គម ដែលជាវិស័យគន្លឹះសម្រាប់ប្រើប្រាស់វិធីសាស្ត្រទាំងនេះមាន :

(i) ការរៀបចំការអនុវត្តការត្រួតពិនិត្យនិងវាយតម្លៃនៃយុទ្ធសាស្ត្រ

(ii) កំណែទម្រង់វិស័យសាធារណៈ និង ដំណើរការទាំងឡាយសម្រាប់គ្រប់គ្រងការចំណាយសាធារណៈ

(iii) គម្រោងអភិវឌ្ឍន៍ដែលដឹកនាំដោយសហគមន៍ និង

(iv) អន្តរាគមន៍ទៅលើវិស័យផ្សេងៗ (ឧទាហរណ៍ដូចជា : វិស័យសុខាភិបាល អប់រំ ការដឹកជញ្ជូន ទឹកស្អាត និងអនាម័យជាដើម) ។

យន្តការទាំងឡាយនោះដែលមានក្នុងចំណោមលំដាប់លំដោយនេះ អាចប្រើ ដើម្បីឱ្យទទួលបានការទទួលខុសត្រូវសង្គម ដែលយន្តការទាំងនោះ ស្វែងរកទំនាក់ទំនងដោយផ្ទាល់ទៅនឹងប្រជាពលរដ្ឋធម្មតានៅក្នុងដំណើរការបែងចែកការចំណាយ លើការត្រួតពិនិត្យនិងការវាយតម្លៃនូវការប្រើប្រាស់ធនធានសាធារណៈ ដែលបានបង្ហាញថាមានប្រសិទ្ធភាពល្អ តាំងពីធនធានទាំងនេះដាក់ចេញជាគោលនយោបាយ ដើម្បីអនុវត្តមក ។ ខាងក្រោមនេះ គឺជាការពន្យល់សង្ខេបមួយនៃវិធីសាស្ត្រទាំងឡាយនៃការទទួលខុសត្រូវសង្គមដែលបានជ្រើសរើស ដែលបានប្រើជាគំនិតចាប់ផ្តើមនៃដំណាក់កាលផ្សេងៗគ្នារបស់គោលនយោបាយសាធារណៈ និង វដ្តនៃការគ្រប់គ្រងការចំណាយសាធារណៈ ។

**ការធ្វើគោលនយោបាយដោយមានការចូលរួម និង ការបង្កើតកញ្ចប់ថវិកា**

កិច្ចការនេះ ជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយប្រជាពលរដ្ឋ/ការចូលរួមរបស់ CSO ក្នុងការបង្កើតគោលនយោបាយសាធារណៈ និង ការបង្កើតកញ្ចប់ថវិកា (ឧទាហរណ៍ដូចជា : ក្នុងការស្នើសុំគម្រោង និងការផ្តល់មូលនិធិ) ។ ការធ្វើគោលនយោបាយដែលមានការចូលរួមបានក្លាយជានិន្នាការកាន់តែទូទៅ ជាពិសេសជាមួយនឹងការបង្ហាញយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅថ្នាក់ជាតិ និងគំនិតផ្តួចផ្តើមនៃការអភិវឌ្ឍដែលដឹកនាំដោយសហគមន៍នៅថ្នាក់មូលដ្ឋាន ។ ការបង្កើតកញ្ចប់ថវិកាដែលមានការចូលរួម គឺ មិនសូវធ្វើជាទូទៅទេ ហើយជាធម្មតាធ្វើឡើងនៅកម្រិតតំបន់ (សាលាក្រុងជាង ១០០ សាលាក្រុងបានចូលរួម នៅប្រទេសប្រេស៊ីល ) ប៉ុន្តែវាអាចអនុវត្តបានជាលក្ខណៈទ្រឹស្តីចំពោះតែថ្នាក់ខ្ពស់ប៉ុណ្ណោះ ។ វិធីសាស្ត្រមួយទៀត ដើម្បីបង្កើតកញ្ចប់ថវិកាដោយមានការចូលរួម គឺ ធ្វើឡើងនៅពេលដែលអ្នកដើរតួនាទីទាំងឡាយក្នុងសង្គមស៊ីវិល រៀបចំកញ្ចប់ថវិកាត្រៀម (ដូចជា កញ្ចប់ថវិការបស់ ស្ត្រីនៅតំបន់អាហ្វ្រិក ឬ កញ្ចប់ថវិកាសហព័ន្ធរបស់ប្រទេសកាណាដា) ។ ទិដ្ឋភាពនេះបានជះឥទ្ធិពលដល់ការបង្កើតកញ្ចប់ថវិកាដោយបង្ហាញពីការគាំទ្ររបស់ប្រជាពលរដ្ឋ ។

**ការធ្វើគោលនយោបាយដោយមានការចូលរួម និង ការវិភាគថវិកា**

ត្រង់ចំណុចនេះ ការត្រួតពិនិត្យថវិការបស់ CSOs ធ្វើឡើងដើម្បីប៉ាន់ប្រមាណថាតើ ការបែងចែកធនធាននោះ សមស្របនឹងអ្វីដែលរដ្ឋាភិបាលបានប្រកាសពីឆន្ទៈសង្គមឬទេ ។ កិច្ចការនេះអាចជាប់ទាក់ទងនឹងការវិភាគនូវឥទ្ធិពល និង ការជាប់ពាក់ព័ន្ធនឹងការផ្តល់ថវិកា ដែលបង្ហាញឱ្យឃើញនូវបញ្ជីបច្ចេកទេសថវិកាដោយឥតលាក់លៀម ការលើកជាចំណេះដឹងពីបញ្ហាដែលជាប់ទាក់ទងនឹងថវិកា និងទទួលរ៉ាប់រងធ្វើយុទ្ធនាការ

អប់រំសាធារណៈ ដើម្បីបង្កើនចំណេះដឹងពីការកសាងថវិកា ។ នៅកម្រិតមូលដ្ឋាន ប្រសិនបើប្រជាពលរដ្ឋដែលបានចូលរួមក្នុងការធ្វើផែនការថវិកា បានខំប្រឹងធ្វើជាសាធារណៈ និងលើកទឹកចិត្តឱ្យមានការចូលរួមពិភាក្សាជុំវិញបញ្ជីថវិកាមូលដ្ឋាន វាអាចបម្រើដល់ការលើកកម្ពស់ការយល់ដឹងសាធារណៈស្តីពីបញ្ហាកសាងថវិកា ព្រមទាំងដាក់កម្រិត និង លើកទឹកចិត្តឱ្យមានការចូលរួមដោយខ្ជាប់ខ្ជួនរបស់ប្រជាពលរដ្ឋទៅក្នុងការអនុវត្ត និង ការត្រួតពិនិត្យ ការកសាងថវិកា ។ CSOs ក៏ដើរតួយ៉ាងសំខាន់ផងដែរក្នុងការពិនិត្យឡើងវិញ ការរិះគន់ទិទៀន និងកសាងចំណេះដឹងសាធារណៈអំពីគោលនយោបាយទាំងឡាយក្នុងផ្នែកសំខាន់ៗ ដូចជាការកាត់បន្ថយភាពក្រីក្រ សមធម៌យេនឌ័រ ការការពារបរិដ្ឋាន ការមានការងារធ្វើ និងសេវាសង្គមផ្សេងៗទៀត ។

**ការតាមដាន ត្រួតពិនិត្យចំណាយសាធារណៈ ដោយមានការចូលរួម/ការតាមដានត្រួតពិនិត្យលទ្ធផល**

កិច្ចការនេះជាប់ទាក់ទងជាមួយការតាមដានត្រួតពិនិត្យរបស់ក្រុមប្រជាពលរដ្ឋ ទៅលើរបៀបដែលរដ្ឋាភិបាលចំណាយមូលនិធិជាក់ស្តែង ជាមួយនឹងគោលបំណងនៃការធ្វើឱ្យលេចធ្លាយ និង/ឬការធ្វើឱ្យកកស្ទះដល់ការបង្ហូរធនធានហិរញ្ញវត្ថុឬលទ្ធផល ។ តួយ៉ាងក្រុមទាំងនេះបានបម្រើឱ្យអ្នកប្រើប្រាស់ពិតប្រាកដ ឬ អ្នកទទួលផលពីសេវារដ្ឋាភិបាល (ជ្រោមជ្រែងដោយ CSOs ) ដើម្បីប្រមូលផ្តុំនិងផ្សព្វផ្សាយជាសាធារណៈនូវទិន្នន័យបានពីលទ្ធផល និង ការចំណាយ ។ វិធីសាស្ត្រនេះជាញឹកញយ ជាប់ទាក់ទងនឹងបច្ចេកទេសបង្កើតគម្លាតព័ត៌មានដែលទទួលបានពីការកត់ត្រាការចំណាយរបស់ក្រសួងហិរញ្ញវត្ថុ ដែលបញ្ជីគណនីបានដាក់ឱ្យដោយភ្នាក់ងារបណ្តាញ និងព័ត៌មានដែលទទួលបានពីការស៊ើបសួរដោយឯករាជ (ឧទាហរណ៍ : ដូចជាការប្រើឧបករណ៍សវនកម្មសង្គម)។ ព័ត៌មានបានផ្សព្វផ្សាយតាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ការបោះពុម្ពផ្សាយ និងការជួបប្រជុំនៅតាមទីសាធារណៈ ។ ការតាមដានត្រួតពិនិត្យដោយមានការចូលរួម លើការចំណាយក្នុងការអប់រំថ្នាក់បឋមនៅ Uganda និងបច្ចេកទេស សវនកម្មសង្គមដែលប្រើប្រាស់ក្រោមការផ្តួចផ្តើមគំនិតត្រួតពិនិត្យតាមដានសង្គមរបស់ Bolivia ជាឧទាហរណ៍របស់វិធីសាស្ត្រមួយដូចជា :

*រូបទី ៣ : ការទទួលខុសត្រូវសង្គម : ឧទាហរណ៍នៃការអនុវត្តតាមរយៈគោលនយោបាយសាធារណៈនិង វដ្តថវិកា*




## ប្រតិបត្តិការពិនិត្យតាមដាន និង វាយតម្លៃដោយមានការចូលរួម

នេះជាតម្រូវការចាំបាច់របស់ក្រុមប្រជាពលរដ្ឋ ឬ ការពិនិត្យតាមដានសហគមន៍ និងការប្រព្រឹត្តរបស់សេវាសាធារណៈទាំងឡាយ ឬគម្រោងទាំងឡាយ និងការវាយតម្លៃនូវឥទ្ធិពលរបស់វា តែងតែធ្វើឡើងដោយយោងទៅតាមអាំងឌីការទ័រដែលគេបានជ្រើសរើសរួច ។ កិច្ចការនេះសម្រេចបានតាមរយៈការប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យតាមដាននិងវាយតម្លៃដោយមានការចូលរួម (ដូចជាការប្រើប្រាស់បណ្ណសហគមន៍) នៅតាមកម្រិតមីក្រូ តាមរយៈការប្រើប្រាស់ការស្ទាបស្ទង់មតិសាធារណៈ ឧទាហរណ៍ ដូចជា ការទទួលដំណឹងជាសាធារណៈ ឬតាមបណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ដែលបានអនុវត្តនៅក្នុងប្រទេសឥណ្ឌា និង ប្រទេសហ្វីលីពីន។ លទ្ធផលនៃការធ្វើការសាកល្បងការត្រួតពិនិត្យតាមដាននិងវាយតម្លៃដោយមានការចូលរួម គឺបានបង្ហាញនៅពេលធ្វើកិច្ចប្រជុំបូកសរុប (ដែលអ្នកប្រើប្រាស់ និង អ្នកផ្តល់សេវាមកជួបជុំគ្នា ដើម្បីពិភាក្សាពីបញ្ហាពិតជាក់ស្តែង និងស្វែងរកដំណោះស្រាយ) ដូចជាករណីបណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ត្រូវបានផ្សព្វផ្សាយជាសាធារណៈ និងបង្ហាញដល់មន្ត្រីរដ្ឋាភិបាល ដើម្បីទាមទាការទទួលខុសត្រូវ និងបញ្ចុះបញ្ចូលឱ្យមានការផ្លាស់ប្តូរ។

បទពិសោធន៍ដំបូងបានបង្ហាញថាវិធីសាស្រ្តនីមួយៗក្នុងចំណោមវីធីសាស្រ្តទាំងនោះ ជាសក្តានុពលដើម្បីកាត់បន្ថយលទ្ធផលប្រតិបត្តិសំខាន់ៗ (ឧទាហរណ៍ដូចជា ការបង្កើននូវការប្រព្រឹត្តិ ការណែនាំនៃការវាស់វែងដោយមានការចូលរួម) ជាលទ្ធផលនៃដំណើរការនេះ (ឧទាហរណ៍ការផ្លាស់ប្តូរស្ថាប័ន ការផ្លាស់ប្តូរឥរិយាបថ និងការផ្លាស់ប្តូរទំនាក់ទំនងជាដើម)។ តាមរយៈបទពិសោធន៍បានបង្ហាញឱ្យយើងផងដែរថា ឥទ្ធិពល និង មុខងារ

បានបង្កើតឡើងនៅពេលដែលវិធីសាស្ត្រជាលក្ខណៈប្រព័ន្ធមួយបានទទួលយក ហើយគំនិតផ្តួចផ្តើមការទទួលខុសត្រូវសង្គមបានគាំទ្រដល់ដំណាក់កាលផ្សេងៗគ្នា តាមរយៈគោលនយោបាយសាធារណៈ និង វដ្តនៃការចំណាយ ។ ជាឧទាហរណ៍នៅក្នុងបរិបទនៃកំណែទម្រង់សង្គមស្តីពីកម្មវិធី វិធីសាស្ត្រមួយចំនួនបានអនុវត្តដូចខាងលើ និង ប្រតិបត្តិដោយកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាព និងជំរុញការបង្កើនការការពារបរិយាកាស សម្រាប់ការទទួលខុសត្រូវសង្គម ឱ្យឆ្ពោះទៅរកអ្វីដែលបានកំណត់ជាប្រព័ន្ធនៃការទទួលខុសត្រូវសង្គមមួយ ។

## ខ. ការទទួលខុសត្រូវសង្គម : កត្តាសំខាន់ទាំងឡាយនាំឱ្យមានជោគជ័យ

ដំណើរការរីកលូតលាស់នៃការផ្តួចផ្តើមគំនិតស្តីពីការទទួលខុសត្រូវសង្គមដ៏ប្រសើរបំផុត បានមកពីការបង្កើតជាលក្ខណៈជាប្រព័ន្ធ ។ ចំពោះផ្នែកនានាជាច្រើន ការវាស់វែងដោយក្រុមប្រជាពលរដ្ឋ ដើម្បីជំរុញឱ្យមានការទទួលខុសត្រូវ គឺជាការឆ្លើយតបប្រកបដោយកាលានុវត្តភាពចំពោះស្ថានភាពដោយឡែក ។ ទោះបីជាយ៉ាងណាក៏ដោយ ជោគជ័យរបស់ពួកគេបានពឹងផ្អែកជាចម្បងលើកត្តាសំខាន់ៗមួយចំនួន ។ កត្តាជោគជ័យទាំងនេះបានលើមក ពិភាក្សាដូចខាងក្រោម :

### បរិបទនយោបាយ និង វប្បធម៌

ព្រំដែនសម្រាប់ការទទួលខុសត្រូវសង្គមគឺកំណត់ជាទូលំទូលាយ ដោយបរិបទនយោបាយនិងវប្បធម៌ដែលមានស្រាប់ ។ ឧទាហរណ៍ដូចជា ភាពដែលអាចធ្វើទៅបាន និងភាពអាចអនុវត្តបាននៃជោគជ័យរបស់គំនិតផ្តួចផ្តើមឱ្យមានការទទួលខុសត្រូវសង្គមពឹងផ្អែកយ៉ាងខ្លាំងលើរបបនយោបាយ ថាតើ ជារបបប្រជាធិបតេយ្យតាមប្រព័ន្ធពហុបក្ស នៅក្នុងរដ្ឋាភិបាលនោះ ដែលសិទ្ធិស៊ីវិលនិងសិទ្ធិនយោបាយជាមូលដ្ឋានត្រូវបានធានា ឬទេ (រួមមាន សិទ្ធិទទួលបានព័ត៌មាន និង សេរីភាពក្នុងការបញ្ចេញមតិ សេរីភាពនៃការបង្កើតសមាគមន៍ និងសេរីភាពនៃការជួបប្រជុំជាដើម) និងថាតើមាន វប្បធម៌ ស្តីពីតម្លាភាពនយោបាយ និង វប្បធម៌សុចរិតភាពឬនៅ។ អត្ថិភាពនៃកត្តាដែលបានលើកឡើងទាំងនេះ និងហានិភ័យ ជាសក្តានុពលដែលអវត្តមាន អាចចោទជាសំណួរឡើងដែលគួរតែដាក់បញ្ចូលនៅក្នុងការគិតពិចារណា នៅពេលធ្វើផែនការការផ្តួចផ្តើមគំនិតឱ្យមានការទទួលខុសត្រូវសង្គម ។ កត្តាច្បាប់ កត្តាស្ថាប័ន កត្តាសេដ្ឋកិច្ច វប្បធម៌ នឹងមានឥទ្ធិពលយ៉ាងសំខាន់ទៅលើភាពជោគជ័យនៃការផ្តួចផ្តើមគំនិតឱ្យមានការទទួលខុសត្រូវសង្គម ។ បរិបទអវិជ្ជមាន ដែលមិនមានន័យថាសកម្មភាពនៃការទទួលខុសត្រូវសង្គម មិនគួរស្វែងរកនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតនៅក្នុងកាលៈទេសៈដូចនេះ ការវិភាគរកកត្តា ចម្បងៗដែលកំពុងមានឥទ្ធិពលលើបរិយាកាសសម្រាប់ការទទួលខុសត្រូវសង្គម (និងហានិភ័យដែលពួកគេជួបជាឧបសគ្គ) គួរតែគេទទួលរ៉ាប់រង និងធ្វើយុទ្ធសាស្ត្រ សមស្របសម្រាប់បង្ហាញឱ្យឃើញនូវឧបសគ្គដែលបានប្រទះ ។

### ការទទួលបានព័ត៌មាន

ដូចបានធ្វើអធិប្បាយខាងលើ ភាពដែលអាចរកបាន និងភាពជឿទុកចិត្តបាននៃឯកសារ និង ទិន្នន័យ

សាធារណៈ គឺចាំបាច់សម្រាប់ការកសាងការទទួលខុសត្រូវសង្គម ។ ព័ត៌មាននេះជាមូលដ្ឋានគ្រឹះសម្រាប់សកម្មភាព នៃការទទួលខុសត្រូវសង្គម ហើយដូចនេះគុណភាព និង ភាពអាចទទួលយកបានរបស់វាគឺជាការបញ្ជាក់ដ៏សំខាន់នៃភាពទទួលបានជោគជ័យរបស់យន្តការនៃការទទួលខុសត្រូវសង្គមផងដែរ ។ នៅក្នុងករណីជាច្រើន កិច្ចខិតខំប្រឹងប្រែងទាំងឡាយ ដើម្បីឱ្យទទួលបានការទទួលខុសត្រូវសង្គមលើកដំបូង អាចតម្រូវឱ្យផ្តោតទៅលើការធានាឱ្យមានសេរីភាពនៃការតាក់តែងច្បាប់ព័ត៌មានដែលបង្ហាញឱ្យឃើញនូវកង្វះខាតឆន្ទៈនយោបាយ ដែលនឹងត្រូវផ្សព្វផ្សាយ ឬ ពង្រឹងនូវសមត្ថភាពបច្ចេកទេសនៃស្ថាប័នសាធារណៈ ដើម្បីកត់ត្រា គ្រប់គ្រង និងឱ្យមានទិន្នន័យពាក់ព័ន្ធ ដែលអាចរកបានផងដែរ ។

## តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយ

ប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញឱ្យមានកាទទួលខុសត្រូវសង្គម ។ នៅក្នុងប្រទេសជាច្រើន ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ គឺជាកម្លាំងដឹកនាំមួយនៅក្នុងការផ្តល់ព័ត៌មាន/ការអប់រំប្រជាពលរដ្ឋ ការត្រួតពិនិត្យតាមដានទង្វើរបស់រដ្ឋាភិបាល និងផ្សាយឱ្យដឹងពីអំពើអាក្រក់ទាំងឡាយ ។ ប្រព័ន្ធផ្សព្វផ្សាយកម្រិតមូលដ្ឋាន (ជាពិសេសវិទ្យុឯកជននិងសហគមន៍) ផ្តល់ជាមធ្យោបាយដ៏សំខាន់មួយ ហេតុដូចនេះប្រជាពលរដ្ឋសាមញ្ញអាចបញ្ចេញសំឡេងជាទស្សនៈយោបល់របស់ពួកគេ និង ពិភាក្សាពីបញ្ហាសាធារណៈទាំងឡាយបាន ។ ការពង្រីកវិសាលភាពនៃប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងឱ្យមានម្ចាស់រួមច្រើន (ជាប់ទាក់ទងម្ចាស់ពីរ-បី) គឺជាកត្តាសំខាន់ដែលអាចបែងចែកការទទួលខុសត្រូវនៃប្រព័ន្ធនយោបាយ ។ ធាតុសាមញ្ញនៃការផ្តួចផ្តើមគំនិត ឱ្យការទទួលខុសត្រូវសង្គមទទួលបានជោគជ័យស្ទើរទាំងស្រុងនោះ គឺការប្រើប្រាស់យុទ្ធសាស្ត្រទាំងទម្រង់តាមបែបទំនើប និងតាមបែបបូរាណ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីផ្តល់ចំណេះដឹងជុំវិញបញ្ហាសាធារណៈ ការផ្តល់មូលនិធិ និងការបង្កើតជាវេទិកាសម្រាប់ការពិភាក្សាសាធារណៈ ។

## ការកសាងសមត្ថភាពសង្គមសង្គមស៊ីវិល

សមត្ថភាពនៃអ្នកដើរតួនាទីក្នុងសង្គមស៊ីវិល គឺជាកត្តាសំខាន់មួយទៀតនៃការទទួលខុសត្រូវសង្គមដោយជោគជ័យ ។ កម្រិតគ្រប់គ្រងរបស់CSOs ព្រំដែននៃសមាជិកភាព ជំនាញតស៊ូមតិនិងបច្ចេកទេសរបស់ពួកគេ សមត្ថភាពរបស់ពួកគេឱ្យចេះរៀបចំនិងប្រើប្រាស់ដោយមានប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយ ភាពត្រឹមត្រូវតាមច្បាប់និងតំណាង និង កម្រិតនៃភាពឆ្លើយតបនិងការទទួលខុសត្រូវចំពោះសមាជិកភាពផ្ទាល់ខ្លួនរបស់ពួកគេ ទាំងអស់គឺជាចំណុចកណ្តាល ដើម្បីទទួលបានភាពជោគជ័យនៃសកម្មភាពនៃការទទួលខុសត្រូវសង្គម ។ ស្ថិតនៅក្នុងបរិបទជាច្រើន កិច្ចខិតខំប្រឹងប្រែង ដើម្បីជំរុញឱ្យមានបរិយាកាសល្អសម្រាប់សង្គមស៊ីវិល និងដើម្បីកសាងសមត្ថភាព (ទាំងផ្នែកគ្រប់គ្រងនិងបច្ចេកទេស) របស់ CSOs តាមតម្រូវការ ។

## ការបញ្ចេញសមត្ថភាពរបស់រដ្ឋ

ភាពជោគជ័យនៃការផ្តួចផ្តើមគំនិតការទទួលខុសត្រូវសង្គម ពឹងផ្អែកផងដែរទៅលើសមត្ថភាព ប្រកបដោយប្រសិទ្ធភាពរបស់រដ្ឋ ។ ការផ្តួចផ្តើមគំនិតការទទួលខុសត្រូវសង្គមបង្ហាញតិចតួច នូវកន្លែងដែលយន្តការរដ្ឋបានធ្លាក់ចុះ ឬ អស់ប្រសិទ្ធភាពទាំងស្រុង ។ ទោះជាយ៉ាងណា ការធ្វើមុខងាររដ្ឋបាលសាធារណៈ

ដែលមានសមត្ថភាពមួយចំនួន ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ គឺជាអ្វីដែលត្រូវធ្វើមុនគេ ។ ទិដ្ឋភាពដទៃទៀតរបស់សមត្ថភាពរដ្ឋ ដែលមានឥទ្ធិពលលើជោគជ័យនៃការផ្តួចផ្តើមគំនិតទទួលខុសត្រូវសង្គម (ហើយនោះអាចតម្រូវឱ្យមានការផ្តល់ អំណាចអភិវឌ្ឍន៏សមត្ថភាពផងដែរ) រួមមាន : សមត្ថភាពចងក្រងឯកសារនិងគិតពិចារណា សមត្ថភាពពង្រីកយន្តការការទទួលខុសត្រូវនូវអនុសញ្ញា (តាមអង្គភាពខ្សែបណ្តោយ) ការប្រគល់អំណាចអនុវត្តន៏របស់អាជ្ញាធរ និងធនធានឆន្ទៈនិងសមត្ថភាពដែលត្រូវកសាងភាពជាដៃគូ/ ការសហការ ព្រមទាំងវប្បធម៌គ្រប់គ្រង និង នយោបាយដែលជាសញ្ញាណតម្លៃរបស់សុចរិតភាពរបស់វិស័យសាធារណៈនៃការទទួលខុសត្រូវសង្គម និង សមធម៌ ។

## ការធ្វើសកម្មភាពរួមគ្នារវាងសង្គមស៊ីវិល និងរដ្ឋ

ជាចុងក្រោយភាពជោគជ័យនៃការផ្តួចផ្តើមគំនិតការនៃការទទួលខុសត្រូវសង្គម ផ្អែកទៅលើទម្រង់អន្តរកម្ម ដ៏មានប្រសិទ្ធភាពមួយចំនួនរវាងសង្គមស៊ីវិល និង រដ្ឋ ។ លទ្ធផលពោរពេញដោយអត្ថន័យគឺទំនងជាអាចសម្រេចបាននៅ ពេលប្រជាពលរដ្ឋ អ្នកនយោបាយ និងមន្ត្រីការិយាធិបតេយ្យទាំងអស់ទទួលបានការលើកទឹកចិត្ត ដើម្បីធ្វើសកម្មភាព ។ Ackerman (នៅឆ្នាំ ២០០៤) បានចង្អុលបង្ហាញថា "សកម្មភាពរបស់រដ្ឋឯកតោភាគី ជាធម្មតាបញ្ចប់ ដោយឧបាយកលបញ្ឆោត ខណៈដែលសកម្មភាពរបស់រដ្ឋឯកតោភាគី ដែលជាញឹកញាយបញ្ចប់ដោយការបង្ក្រាបនិងដោយអំពើហិង្សា ដែលធ្វើឡើងដោយរដ្ឋ " ហើយបន្ថែមថា " លទ្ធផលជាផ្លែផ្កា ភាគច្រើនបានកើតឡើងនៅពេលភាគីទាំងពីរចូលរួមធ្វើដោយសកម្ម " គាត់បានបញ្ជាក់ទៀតថា ការចូលរួមទៅវិញទៅមកមិនត្រឹមតែជាជោគជ័យ ផ្អែកលើការព្រមព្រៀងប៉ុណ្ណោះទេ ថែមទាំងជាការពិតជាក់ស្តែង ហើយសូម្បីតែ " ជម្លោះនិងការមន្ទិលសង្ស័យ " ក៏អាចដឹកនាំទៅរកសកម្មភាពរួមគ្នារវាងសង្គមស៊ីវិល និង រដ្ឋផងដែរ ។ តាមរយៈមេរៀននេះបង្ហាញថា ការផ្តួចផ្តើមគំនិតនៃការទទួលខុសត្រូវសង្គម គួរតែរួមបញ្ចូលគ្នាទាំងភាគីរដ្ឋ និងអ្នកដើរតួសកម្មភាពក្នុងសង្គម ព្រមទាំងផ្តោតជាសំខាន់ទៅលើការបង្រួមចូលគ្នារវាងពួកគេទាំងពីរភាគី ។(Ackerman, ឆ្នាំ២០០៤ ទំព័រទី ៧)

## ការបង្កើតជាស្ថាប័ន

ខណៈដែល *ad hoc* ឬការផ្តួចផ្តើមគំនិតការទទួលខុសត្រូវសង្គមកំពុងធ្វើឡើងដែលអាចធ្វើឱ្យមានភាពខុសគ្នា បទពិសោធន៏បានចង្អុលបង្ហាញថាផលប៉ះពាល់កាន់ធំ និងស្ថិតជានិរន្តរ៍បំផុត នៅពេលដែលយន្តការនៃការទទួលខុសត្រូវសង្គមបានកើតជា "ស្ថាប័នមួយ" ដែលនិយាយម្យ៉ាងទៀតបានបង្កប់ចូលជ្រៅក្នុងការអនុវត្តជាប្រព័ន្ធដោយអង្គការសង្គមស៊ីវិល រដ្ឋ ឬស្ថាប័ន " ស្ថាប័នកូនកាត់ "។ ដូចដែលបានពិភាក្សាខាងដើមយន្តការ " ខាងក្រៅ " នៃការទទួលខុសត្រូវសង្គម អាចមានប្រសិទ្ធភាពជាពិសេស នៅពេលបូកបញ្ចូលយន្តការការទទួលខុសត្រូវ " ខាងក្នុង " ចំពោះរដ្ឋ ។ យោងតាម Fox 9ឆ្នាំ ២០00 ទំព័រទី ១) "ការទាមទាររបស់សង្គមស៊ីវិលចំពោះរដ្ឋ ភាគច្រើនបង្ហាញពី ការទទួលខុសត្រូវ នៅពេលពួកគេផ្តល់អំណាច ត្រួតពិនិត្យនិងថ្លឹងថ្លែងអំណាចរដ្ឋ" ។

ជាលទ្ធផល ក្រៅពីការស្វែងរកលទ្ធផលប្រតិបត្តិជាក់លាក់ទាំងឡាយ ការផ្តួចផ្តើមគំនិតការទទួល

ខុសត្រូវសង្គម គួរតែយកចិត្តទុកដាក់ផងដែរដល់កត្តាស្ថាប័ន និងត្រូវស្វែងរកឱកាសសម្រាប់ឱ្យមានឥទ្ធិពលយូរអង្វែងដល់ការអភិវឌ្ឍនិង/ឬក៏កំណែទម្រង់ស្ថាប័ន ។ ការផ្តួចផ្តើមគំនិតការទទួលខុសត្រូវសង្គម តែងតែកំណត់ពីតម្រូវការសម្រាប់ការផ្លាស់ប្តូរស្ថាប័ននៅក្នុងភ្នាក់ងាររដ្ឋាភិបាល និងសេវាសាធារណៈ (ឧទាហរណ៍ការផ្លាស់ប្តូរឥរិយាបថ អាកប្បកិរិយារបស់បុគ្គលិកជួរមុខពីការទទួលការលើកទឹកចិត្ត និង ការដាក់ទណ្ឌកម្មរបស់អង្គភាពពិសេសមួយ របៀបគ្រប់គ្រងរបស់វា ឬដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តជាដើម ។ល ។) ពួកគេអាចដាក់បន្ថែម ព្រមទាំងដើតួនាទីយ៉ាងសំខាន់ក្នុងការនាំមកនូវការផ្លាស់ប្តូរទាំងនេះ (ឧទាហរណ៍ ដោយភ្ជាប់ជាមួយនូវបុគ្គលិកមណ្ឌលសុខភាពទៅស្វែងរកដោយទៀងទាត់ និងក្តាប់បានព័ត៌មានពីអ្នកជំងឺ ឈានទៅបង្កើតនូវគណៈកម្មការតម្លាភាពរបស់ប្រជាពលរដ្ឋសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលមូលដ្ឋាន ឬ ធ្វើការណែនាំក្រុមតាមដានត្រួតពិនិត្យសង្គម ដើម្បីវាយតម្លៃលើទង្វើរបស់កម្មវិធីថ្នាក់ជាតិ ឬ លើគោលនយោបាយដែលកំពុងបន្ត) ។ កន្លែងអាចបង្កើតស្ថាប័នស្របច្បាប់នៃយន្តការបាន ដោយមានការចូលរួមពីកម្រិតកម្មវិធីជាបុគ្គលនិងភ្នាក់ងារទាំងឡាយឆ្លងតាមកម្រិតប្រព័ន្ធទាំងមូល គួរតែចាត់ទុកថាជាមធ្យោបាយមួយ ដើម្បីជំរុញឱ្យមានប្រសិទ្ធភាព និង ស្ថេរភាពយូរអង្វែង ។

## ច. សេចក្តីសន្និដ្ឋាន

ភស្តុតាងនៃស្ថាប័នដែលកំពុងរីកលូតលាស់ឡើង បង្ហាញថា ការទទួលខុសត្រូវសង្គម បានខិតខំប្រឹងប្រែងធ្វើលើផ្នែកប្រជាពលរដ្ឋ និង អង្គការសង្គមស៊ីវិលដែលអាចបម្រើឱ្យបង្កើតនូវយន្តការនៃការទទួលខុសត្រូវតាមខ្សែឈរដ៏មានប្រសិទ្ធភាពថ្មីមួយបាន និង ដើម្បីពង្រឹងយន្តការតាមខ្សែបណ្តោយដែលមានស្រាប់ ។ ការត្រឡប់ នេះនឹងហុចលទ្ធផលកាន់តែប្រសើរឡើងនៅក្នុងអភិបាលកិច្ចល្អ ដើម្បីបង្កើន ការផ្តល់សេវាសាធារណៈ និង ពង្រឹងប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ ។

បទនិពន្ធនេះបានព្យាយាមណែនាំនូវបទបញ្ញត្តិ នៃការទទួលខុសត្រូវសង្គម ដែលវាកំពុងតែលេចឡើងជាវិស័យមួយ អាចទទួលបានជោគជ័យសម្រាប់ធនាគាពិភពលោក ជាពាក្យដែលប្រើសម្គាល់ទាំងការផ្តល់អំណាចនិងសកម្មភាពគ្រប់គ្រងប្រកបដោយចំណេះដឹង ។ ជាមួយការផ្លាស់ប្តូរឆ្ពោះទៅមុខការ គាំទ្រថវិកា និងគោលនយោបាយ ដោយបានផ្អែកលើមូលដ្ឋានមូលនិធិដែលកំពុងឱ្យខ្ចី ធនាគារពិភពលោកនិងក្រុមអ្នកផ្តល់ជំនួយដទៃផ្សេងទៀត កំពុងលើកទឹកចិត្ត ធ្វើឱ្យមានប្រព័ន្ធនៃការទទួលខុសត្រូវក្នុងប្រទេសកាន់តែបរឹងមាំ ដែលជាតម្រូវការដំបូងសម្រាប់ភាពដែលអាចស្ថិតស្ថេរបាន របស់ទម្រង់នៃជំនួយអភិវឌ្ឍន៍ ។ ស្ថិតនៅក្នុងបរិបទនេះ តួនាទីចូលរួមដោយផ្ទាល់របស់ប្រជាពលរដ្ឋ និង ការជាប់ទាក់ទងរបស់សង្គមស៊ីវិលនៅក្នុងការតាមដានត្រួតពិនិត្យ និងការទទួលខុសត្រូវ នឹងក្លាយកាន់តែសំខាន់ថែមទៀត ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការអភិវឌ្ឍ ។ នៅទីនេះវាបង្ហាញយ៉ាងច្បាស់លាស់ថា យន្តការនៃការទទួលខុសត្រូវសង្គមអាចដើរតួនាទីជាផ្នែកមួយដ៏សំខាន់ ។

ហេតុដូច្នេះ ធនាគារពិភពលោកកំពុងតែជំរុញនិងគាំទ្រកាន់តែខ្លាំងថែមទៀត ដល់សកម្មភាពការទទួលខុសត្រូវសង្គម នៅក្នុងចំណោមប្រទេសមួយចំនួន រួមមាន :ប្រទេស Argentina, Armenia, Benin, Ghana, Honduras, India, Malawi, Peru, Philippines, Russia, Senegal, Sri Lanka, Uganda និង ប្រទេស Vietnam ។ ការធ្វើអន្តរាគមន៍ទាំងនេះរួមមានការគាំទ្រចំពោះការផ្តួចផ្តើមគំនិតដោយឯករាជ្យ ដែលធ្លាប់បានអនុវត្តដោយ CSOs ឱ្យមានការយល់ជ្រាបរបស់រដ្ឋាភិបាល និងឱ្យមានការកសាងសមត្ថភាព ការចែករំលែកបទពិសោធន៍និងមេរៀនដែលបានជួបប្រទះកន្លងមក និងការណែនាំបង្ហាញនៃយន្តការនៃការទទួលខុសត្រូវសង្គមស្ថិតនៅក្នុងក្របខ័ណ្ឌធនាគារពិភពលោកដែលបានគាំទ្រគម្រោងកម្មវិធី និងការធ្វើគោលនយោបាយផ្សេងៗ។ ដូចដែលបានពោលខាងលើ សម្រាប់គោលបំណងរយៈពេលយូរអង្វែង គឺធ្វើឱ្យមានយន្តការនៃការទទួលខុសត្រូវសង្គម ដែលបង្កើតជាស្ថាប័ន ជាផ្នែកមួយនៃប្រព័ន្ធផ្គត់ផ្គង់សេវាសាធារណៈនិងអភិបាលកិច្ចល្អ ដែលកំពុងមានធ្វើដូច្នេះ ដើម្បីធានាឱ្យកាន់តែប្រសើរឡើងនូវការទទួលខុសត្រូវរបស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋរបស់គេ នៅក្នុងគ្រប់វិស័យទាំងអស់របស់រដ្ឋ ។